**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droitet des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឌី ផានិត**

**ហ៊ុន សុវណ្ណាវីន**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droitet des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឌី ផានិត**
**ហ៊ុន សុវណ្ណាវីន**

សាស្ត្រាចារ្យណែនាំ
លោកបណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឌី ផានិត** និង **ហ៊ុន សុវណ្ណាវីន** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១២ ឆ្នាំសិក្សា២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច។

សូមសំដែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ

| | |
|---|---|
| លោកឪពុក **ឌី ឱនណា** | លោកឪពុក **ហ៊ុន សុវណ្ណ** |
| អ្នកម្តាយ **ខេង ភាត** | អ្នកម្តាយ **សរ តិនុនរិន្ទ** |

ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងប្រៀនប្រដៅដល់រូបយើងខ្ញុំប្រកបដោយព្រហ្មវិហារធម៌និង បានចំណាយថវិកាជាច្រើនដល់រូបកូនដើម្បីបន្តការសិក្សារហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរសព្រឹទ្ធបុរសរងលោក-លោកស្រីសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា ទាំងកំលាំងកាយ កំលាំងចិត្ត និងយកចិត្តទុកដាក់បង្ហាត់បង្រៀន ប្រៀនប្រដៅដល់រូបយើងខ្ញុំដោយព្រហ្មវិហារធម៌ រហូតដល់បានបញ្ចប់ការសិក្សាដោយជោគជ័យ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្រ្តាចារ្យ បណ្ឌិត **អ៊ុំន សកក្កដា** ដែលលោកបានយកចិត្តទុកដាក់អស់ពីកំលាំងកាយចិត្តក្នុងការណែនាំ ការសរសេរសារណានេះដល់រូបយើងខ្ញុំប្រកបដោយជោគជ័យ។

លើសពីនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់**លោកប្រធាន អនុប្រធាន ថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកទាំងអស់ នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីសៀមរាប** ដែលបានអនុញ្ញាតដល់យើងខ្ញុំទាំងពីរ បានចុះសិក្សាស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងសារណានេះ ដែលបានចំណាយពេលណែនាំ និងផ្តល់ជាឯកសារចាំបាច់ដល់យើងខ្ញុំទាំងពីរ។

ជាចុងក្រោយយើងខ្ញុំសូមប្រសិទ្ធពរ សិរីមង្គលបវរមហាប្រសើរកើតមានដល់ លោកអ្នកមានគុណ លោក-លោកស្រីសាស្រ្តាចារ្យទាំងអស់ អោយជួបប្រទះតែពុទ្ធពរព្រះទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

គោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជាក្នុងការរៀបចំផ្នែកដីធ្លីឱ្យស្របតាមបរិបទនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ហេតុនេះហើយវាបានជំរុញទឹកចិត្តយើងខ្ញុំជានិស្សិតឱ្យចាប់យកប្រធានបទមួយស្តីពី "**ការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាបពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**" ដើម្បីសិក្សាស្វែងយល់ និងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រយៈពេល ៤ឆ្នាំ ចាប់ពីឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៩ ដោយឈរលើចំណេះដឹងដែលយើងខ្ញុំបានទទួលពីការខិតខំបង្ហាត់បង្រៀនពីសំណាក់ លោកគ្រូ-អ្នកគ្រូជាសាស្ត្រាចារ្យទាំងអស់ និងបទពិសោធស្រាវជ្រាវនៅក្នុងការសិក្សាកន្លងមក។

ការលើកយកប្រធានបទស្តីពី "**ការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាបពីឆ្នាំ២០១៤ដល់ ឆ្នាំ២០១៨**" មកធ្វើការសិក្សាស្រាវជ្រាវ សរសេរជាសារណា គឺដោយសារយើងខ្ញុំចង់ដឹងច្បាស់ពីរបៀប និងនីតិវិធីនៃការចុះបញ្ជីដីធ្លីនៅក្នុងខេត្តសៀមរាប ក៏ដូចជាការចង់ដឹងពីមូលហេតុដែលនាំឱ្យមានការកើតឡើងនូវបញ្ហាជម្លោះដីធ្លី បញ្ហាប្រឈមដែលបានកើតឡើងក្នុងការអនុវត្តការចុះបញ្ជីដីធ្លីនៅក្នុងខេត្តសៀមរាប ។

ការរៀបចំសរសេរសារណានេះឡើង ក្នុងគោលបំណងស្វែងយល់ឱ្យបានទូលំទូលាយពីការរៀបចំដីធ្លី និងចងក្រងឯកសារស្នាដែសម្រាប់ផ្តល់ជាប្រយោជន៍ខ្លះៗដល់ប្អូនៗនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់តាមការចាំបាច់ ជាពិសេសយើងខ្ញុំចង់បង្ហាញអំពីនីតិវិធី និងសារៈប្រយោជន៍នៃការចុះបញ្ជីដីធ្លី ។

យើងខ្ញុំជឿជាក់ថា ការសរសេរសារណានេះឡើង ប្រាកដជាមិនទាន់មានភាពពេញលេញល្អត្រឹមត្រូវ គ្រប់ជ្រុងជ្រោយនៅឡើយទេ ជាក់ជាមានកំហុសឆ្គង ក៏ដូចជាកង្វះខាតណាមួយបានកើតឡើងជាក់ជាមិនខាន ។ រាល់កំហុសឆ្គង និងកង្វះខាតដែលបានកើតឡើងនៅក្នុងការតាក់តែងឡើងនៃសារណានេះ យើងខ្ញុំសង្ឃឹមថានឹងមានការយោគយល់ អធ្យាស្រ័យពីសំណាក់លោកគ្រូ-អ្នកគ្រូ ក៏ដូចជាមិត្តនិស្សិត អ្នកអានទាំងអស់ ហើយយើងខ្ញុំក៏សុំធ្វើការខន្តី អភ័យទោសជាមុនផងដែរ ។

**មាតិកា** **ទំព័រ**

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១ ស្ថានភាពទូទៅនៅខេត្តសៀមរាប និងការវិវត្តការចុះបញ្ជីដីធ្លី** ...... ៤

**១.១ទីតាំងភូមិសាស្ត្រក្នុងខេត្តសៀមរាប** ............ ៤

១.១.១ ទីតាំងភូមិសាស្ត្រ និងដង់ស៊ីតេប្រជាជនក្នុងខេត្តសៀមរាប ............ ៤

១.១.២ ការប្រកបមុខរបររបស់ប្រជាជនក្នុងខេត្តសៀមរាប ............ ៥

**១.២ ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន** ............ ៦

**១.៣ បទបញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលគាំទ្រដល់ដំណើរការនៃការចុះបញ្ជីដីធ្លី** ៧

១.៣.១ ការចាត់ចំណាត់ថ្នាក់ដីតាមច្បាប់ភូមិបាល ២០០១ ............ ៨

១.៣.២ គោលការណ៍ដើម្បីទទួលបានកម្មសិទ្ធិដីធ្លី ............ ១០

១.៣.៣ និយមន័យកម្មសិទ្ធិ ............ ១១

**១.៤ សមត្ថកិច្ច និងភារកិច្ចរបស់អភិបាលខេត្ត ក្រុង** ............ ១៤

**ជំពូកទី ២ អំពីការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប** ............ ១៧

**២.១ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ** ............ ១៧

២.១.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ............ ១៧

២.២.១.១ ដំណាក់កាលស្តីពីការរៀបចំ ............ ១៧

២.១.១.២ ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ............ ១៨

២.១.១.៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ............ ២០

២.១.១.៤ អំពីការសម្រេចលើឯកសារ ............ ២២

២.១.១.៥ អំពីការចេញប័ណ្ណ ............ ២៣

២.១.២ សមិទ្ធិផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធការងាររដ្ឋបាលដីធ្លី ............ ២៥

២.១.៣ បញ្ហាប្រឈម ............ ២៧

**២.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ** ............ ២៨

២.២.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ............................................២៩
២.២.១.១ ការដាក់ពាក្យស្នើសុំចុះបញ្ជី.....................................................................២៩
២.២.១.២ អំពីកិច្ចប្រតិបត្តិការបច្ចេកទេស................................................................ ៣១
២.២.១.៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ........................... ៣៤
២.២.១.៤ ការសម្រេចលើឯកសារ..........................................................................៣៥
២.២.១.៥ អំពីការចេញប័ណ្ណ................................................................................ ៣៦
២.២.១.៦គោលការណ៍នៃការចេញប័ណ្ណ.................................................................៣៧
២.២.២ សមិទ្ធិផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ....................................... ៤១
២.២.៣ បញ្ហាប្រឈម........................................................................................... ៤១
**សេចក្តីសន្និដ្ឋាន** ............................................................................................ ៤៤
**អនុសាសន៍** .................................................................................................. ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសំគាល់អក្សរកាត់

| | | |
|---|---|---|
| អ.ន.ក្រ | : | អនុក្រឹត្យ |
| ស.ជ.ណ | : | សេចក្តីជូនដំណឹង |
| ប្រ.ក | : | ប្រកាស |
| ប.ក | : | បង្កើត |
| ដ.ន.ស | : | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី |
| ការិ.ដ.ន.ស.ភ | : | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង |
| ម$^{២}$ | : | ម៉ែត្រការេ |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

- **លំនាំនៃការស្រាវជ្រាវ**

ដីធ្លីជាចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៃព្រះរាជាណាចក្រកម្ពុជា ។ វិស័យដីធ្លីនៅក្នុងប្រទេសកម្ពុជាមានការវិវត្តិពីសម័យកាលមួយទៅសម័យកាលមួយ តាមការផ្លាស់ប្តូរនៃរបបនយោបាយនៃការគ្រប់គ្រងរដ្ឋ ។

នៅមុនសម័យអាណានិគមនិយមបារាំងដីធ្លីទាំងឡាយនៅក្នុងប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រតែមួយអង្គប៉ុណ្ណោះ។ លុះមកដល់សម័យអាណានិគមបារាំង ( ១៨៦៣ ដល់ ១៩៥៣ ) បារាំងបានធ្វើឯកជនភាវូបនីយកម្មលើដីធ្លីជាលើកដំបូង ដោយនៅឆ្នាំ ១៩២០ ក្រមរដ្ឋប្បវេណីដំបូងបំផុតនៃកម្ពុជាត្រូវបានដាក់ឱ្យប្រើប្រាស់ ដែលមានចែងពីសិទ្ធិកម្មសិទ្ធិ និងភោគៈ[1] ។ នាសម័យកាលក្រោយបារាំង ប្រទេសកម្ពុជានៅតែអនុវត្តរបបកម្មសិទ្ធិឯកជន តែជាអកុសលនៅឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ សិទ្ធិកម្មសិទ្ធិត្រូវបានលុបបំបាត់ទាំងស្រុង ។

ក្រោយផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ( ១៩៧៥ ដល់ ១៩៧៩ ) នាឆ្នាំ ១៩៨៩ របបដីធ្លីត្រូវបានដាក់ឱ្យទទួលស្គាល់ជាដំណាក់កាលៗឡើងវិញ ហើយរាល់កម្មសិទ្ធិមុនឆ្នាំ ១៩៧៩ មិនត្រូវបានរដ្ឋទទួលស្គាល់ឡើយ ។ បន្ទាប់មក នៅឆ្នាំ ១៩៩២ ច្បាប់ភូមិបាលថ្មីមួយត្រូវបានបង្កើតឡើង និងត្រូវបានដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី១១ សីហា ១៩៩២ ដោយច្បាប់នេះមានគោលដៅចាត់ថ្នាក់ទ្រព្យសម្បត្តិរដ្ឋ ឯកជន និងសិទ្ធិសំខាន់នានានៃសិទ្ធិកម្មសិទ្ធិលើដីធ្លី ឱ្យកាន់តែរឹងមាំ។

នៅឆ្នាំ១៩៩៣ប្រទេសកម្ពុជាបានប្តូរមកជា ព្រះរាជាណាចក្រកម្ពុជា តាមរយៈរដ្ឋធម្មនុញ្ញថ្មីមួយ ដែលត្រូវបានបង្កើតដោយសភាធម្មនុញ្ញ តាមរយៈការបោះឆ្នោតជាសកលដោយមានការជួយរៀបចំពីសំណាក់អ៊ុនតាក់ UNTAC ។ បន្ទាប់មក នៅឆ្នាំ ២០០១ រដ្ឋសភាបានតាក់តែងច្បាប់ភូមិបាលថ្មីមួយឡើងដោយមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិ លើអចលនវត្ថុទាំងឡាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិនិងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៃកម្ពុជា[2] ។

- **ចំណោទបញ្ហានៃការស្រាវជ្រាវ**

នៅប្រទេសកម្ពុជាចំពោះរបបសិទ្ធិកម្មសិទ្ធិវិញទោះបីជាមានបទដ្ឋានគតិយុត្តផ្សេងៗជាច្រើនគាំពារក៏ដោយ រហូតមកដល់បច្ចុប្បន្ននេះ យើងសង្កេតឃើញថាបញ្ហាជម្លោះដីធ្លីនៅតែជាបញ្ហានៅក្នុងប្រទេសកម្ពុជា ។ ជាពិសេសការចុះបញ្ជីដីធ្លីគឺមិនទាន់មានលក្ខណៈល្អគ្រប់គ្រាន់នៅឡើយទេ

[1] សាស្ត្រាចារ្យ ហាប់ ដល្វី, "នីតិទ្រព្យសម្បត្តិ" ២០១៥
[2] ច្បាប់ភូមិបាល, នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា ១

មិនត្រឹមតែនៅក្នុងខេត្តសៀមរាបប៉ុណ្ណោះនោះទេ ម្យ៉ាងវិញទៀតការចុះបញ្ជីដីនៅក្នុងប្រទេសកម្ពុជាទាំងមូលក៏នៅមានដីជាច្រើនដែលមិនទាន់បានចុះបញ្ជីផងដែរ។ ហេតុដូចនេះ ទើបជម្លោះដីធ្លីកើតមានឡើងជារឿយៗ។

ដោយមើលឃើញពីបញ្ហាទាំងអស់នេះ ទើបមានចំណោទមួយចំនួនបានលើកឡើងថា៖ តើនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈយ៉ាងដូចម្តេច? តើការចុះបញ្ជីបានជួបប្រទះបញ្ហាអ្វីខ្លះ?

- **គោលបំណងនៃការស្រាវជ្រាវ**

គោលបំណងនៃការស្រាវជ្រាវរបស់យើងខ្ញុំគឺពន្យល់អំពីនីតិវិធីនៃការចុះបញ្ជីដីធ្លី ជាពិសេសនៅក្នុងខេត្តសៀមរាបផ្ទាល់តែម្តង។លើសពីនេះទៅទៀត យើងខ្ញុំមានគោលបំណងចូលរួមចំណែកដោះស្រាយជម្លោះក្នុងការកាន់កាប់ដីធ្លី និងពន្យល់ណែនាំប្រជាជននៅក្នុងខេត្តសៀមរាបអោយដឹងកាន់តែច្បាស់អំពីនីតិវិធី និងការកាន់កាប់ដីធ្លីដោយត្រឹមត្រូវ និងស្របច្បាប់ផងដែរ ។ បន្ថែមពីនេះយើងខ្ញុំនឹងធ្វើការស្រាវជ្រាវអំពីបញ្ហាប្រឈមក្នុងការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប និងចូលរួមផ្តល់ជាដំណោះស្រាយតាមរយៈការស្រាវជ្រាវនេះ។

- **ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ចំពោះការស្រាវជ្រាវរបស់យើងខ្ញុំនឹងពណ៌នាអំពីនីតិវិធីនៃការចុះបញ្ជីលើកដំបូងនៅក្នុងខេត្តសៀមរាបចាប់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨តែប៉ុណ្ណោះ ដោយមិនមានវិសាលភាពគ្រប់ដណ្តប់ទូទាំងប្រទេសទេ។ ហើយយើងខ្ញុំក៏មិននិយាយលំអិតទៅលើការប្រើប្រាស់ឧបករណ៍សំរាប់ធ្វើការវាស់វែងដីនិងការកំណត់ទំហំក្បាលដីដែរ។

- **សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះគឺពិតជាមានសារៈសំខាន់ណាស់ចំពោះរូបយើងខ្ញុំ និងអ្នកសិក្សាជំនាន់ក្រោយសំរាប់ជាឯកសារជំនួយ និងអាចសិក្សាបន្ថែមអំពីការចុះបញ្ជីដីធ្លីនៅខេត្តសៀមរាប និងអាចយល់អំពីនីតិវិធីក្នុងការចុះបញ្ជីដីផងដែរ។ លើសពីនេះទៅទៀតក៏អាចជាឯកសារសំរាប់ជំនួយដល់ប្រជាពលរដ្ឋអោយបានយល់ដឹងកាន់តែច្បាស់សារៈប្រយោជន៍ពីការចុះបញ្ជីដីនិងដើម្បីដោះស្រាយជម្លោះដីធ្លី និងការកាន់កាប់ដីធ្លីរបស់ខ្លួនអោយបានត្រឹមត្រូវនិងស្របច្បាប់។

- **វិធីសាស្ត្រស្រាវជ្រាវ**

ដើម្បីធ្វើការស្រាវជ្រាវប្រធានបទមួយនេះអោយបានស៊ីជម្រៅ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវលើគ្រប់ឯកសារ និងបទដ្ឋានគតិយុត្តទាំងអស់ដែលពាក់ព័ន្ធដូចជា៖ ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ សេចក្តីជូនដំណឹង និងតាមរយៈប្រព័ន្ធអ៊ីនធឺណែតផងដែរ ។

លើសពីនេះទៅទៀត យើងខ្ញុំបានចុះទៅស្រាវជ្រាវឯកសារដោយផ្ទាល់នៅ **មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប** ផងដែរ ។

- **រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ចំពោះសារណានេះយើងខ្ញុំធ្វើការបែងចែកជា **ពីរជំពូក** រួមមានៈ

**ជំពូកទី១៖ ទិដ្ឋភាពទូទៅរបស់ខេត្តសៀមរាប និង ការវិវត្តការចុះដីធ្លី**

**ជំពូកទី២៖ អំពីការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប**

ចំពោះខ្លឹមសារ ដែលពាក់ព័ន្ធទៅនឹងចំណោទបញ្ហាដែលបានលើកឡើងខាងលើ និងរាល់ចំណុចទាំងអស់ដែលយើងខ្ញុំបានលើកឡើងខាងលើ យើងខ្ញុំនឹងធ្វើការពណ៌នាខ្លឹមសារលំអិតក្នុងការស្រាវជ្រាវនេះ។

# ជំពូកទី១ ស្ថានភាពទូទៅនៅខេត្តសៀមរាប និងការវិវត្តការចុះបញ្ជីដីធ្លី

## ១.១ទីតាំងភូមិសាស្ត្រក្នុងខេត្តសៀមរាប

### ១.១.១ ទីតាំងភូមិសាស្ត្រ និងដង់ស៊ីតេប្រជាជនក្នុងខេត្តសៀមរាប

ខេត្តសៀមរាប ជាខេត្តមួយដែលមានទីតាំងនៅភាគខាងពាយ័ព្យនៃប្រទេសកម្ពុជាហើយស្ថិតនៅក្បែរបឹងទន្លេសាប។ទីរួមខេត្តរបស់ខេត្តនេះគឺ **ក្រុងសៀមរាប**។ រីឯការដាក់ឈ្មោះថាសៀមរាបនេះ គឺដើម្បីរំលឹកដល់ជ័យជំនះរបស់កងទ័ពខ្មែរលើកងទ័ពសៀម ឬព្រះរាជាណាចក្រថៃនាពេលបច្ចុប្បន្ន នៅក្រុងអយុធ្យានាសតវត្សទី១៧។ ចំនែកកេរ្តិ៍ឈ្មោះខេត្តនេះវិញ ត្រូវបានគេស្គាល់ទូទាំងពិភពលោកថា ជាខេត្តដែលមានសំណង់ដ៏អស្ចារ្យគឺ**ប្រាសាទអង្គរ**។

គួររំលឹកផងដែរថារាជធានីរបស់ប្រទេសកម្ពុជាត្រូវបានពីប្តូរពីអង្គរទៅភ្នំពេញនៅឆ្នាំ ១៤៣២ រួចទៅលង្វែក និង ឧដុង្គ និងត្រលប់ទៅភ្នំពេញវិញនៅឆ្នាំ ១៨៦៦។ ថ្មីៗនេះ ក្រុងសៀមរាបកំពុងប្រែក្លាយរូបរាងជាក្រុងទំនើបតាមរយៈកំណើនសណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ ជាដើមដែលបម្រើអោយវិស័យទេសចរណ៍។ខេត្តនេះជាតំបន់ដ៏មានប្រជាប្រិយដែលទាក់ទាញភ្ញៀវទេសចរណ៍បរទេសឱ្យចូលមកទស្សនារាប់លាននាក់ក្នុង១ឆ្នាំៗ ដោយសារតែមានប្រាសាទបុរាណ និងសម្រស់ធម្មជាតិស្រស់ត្រកាល។

ខេត្តសៀមរាប ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៦ ដែលមានចំងាយប្រវែង ៣១៤ គ.ម ពីទីក្រុងភ្នំពេញ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ធំ និងខេត្តព្រះវិហារ, ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ, ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ, និងខាងត្បូងជាប់នឹងខេត្តបាត់ដំបង និងបឹងទន្លេសាប ។ ព្រំប្រទល់ខេត្តសៀមរាបដែលជាប់បឹងទន្លេសាបមានប្រវែង ៨២ គ.មដែលស្ថិតនៅជាប់ស្រុកជីក្រែង, ស្រុកសូត្រនិគម, ស្រុកប្រាសាទបាគង, ស្រុកសៀមរាបស្រុកពួកនិងស្រុកក្រឡាញ់ ។

តំបន់ខាងលើសំបូរទៅដោយព្រៃភ្នំមានសណ្ឋានដូចជាដីទួលឬខ្ពង់រាប ខ្វះខាតទឹកនិងជួបប្រទះគ្រោះរាំងស្ងួតញឹកញាប់ តំបន់កណ្តាលជាវាលស្រែល្វឹងល្វើយ និងលំនៅឋានព្រមទាំងប្រាង្គប្រាសាទនានា និងតំបន់ក្រោមជាវាលទំនាបរងទឹកជំនន់រៀងរាល់ឆ្នាំ។ ខេត្តសៀមរាបជាតំបន់មានទាំងភ្លៀងធ្លាក់ជន់លិចលង់មានទាំងតមបន់គ្មានភ្លៀងស្ងួតហួតហែង។ ខេត្តសៀមរាបមានផ្ទៃក្រលាសរុបប្រមាណ ១២.០១៥ គ.ម២ ចែកចេញជា ១២ស្រុក ១០០ឃុំ និង៩០៧ភូមិ។ ស្រុកទាំង ១២ មាន៖

១.ស្រុក អង្គរជុំ

២.ស្រុក អង្គរធំ

៣.ស្រុក បន្ទាយស្រី

៤.ស្រុក ជីក្រែង

៥.ស្រុក ក្រឡាញ់

៦.ស្រុក ពួក

៧.ស្រុក ប្រាសាទបាគង

៨.ស្រុក វ៉ារិន

៩.ស្រុក សៀមរាប

១០.ស្រុក សូទ្រនិគម

១១.ស្រុក ស្រីស្នំ

១២.ស្រុក ស្វាយលើ

ខេត្តសៀមរាបមានប្រជាជនចំនួន ៨៩៦៣០៩ នាក់ (2008) ដង់ស៊ីតេប្រជាជន ៨៧នាក់/គីឡូម៉ែតការ៉េ។

### ១.១.២ ការប្រកបមុខរបររបស់ប្រជាជនក្នុងខេត្តសៀមរាប

ប្រជាជននៅខេត្តសៀមរាបមានមុខរបរនិងមានការងារធ្វើច្រើន ពីព្រោះខេត្តនេះជាតំបន់ទេសចរណ៍ដែលមានជនបរទេសមកទស្សនាជារៀងរាល់ថ្ងៃ ដែលអំណោយផលដល់ប្រជាពលរដ្ឋដោយមិនចាំបាច់ធ្វើចំណាកស្រុកទៅប្រទេសក្រៅ។ ស្ថិតនៅក្នុងក្រុងសៀមរាប គេសង្កេតឃើញថាមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ជាច្រើនដើម្បីបំពេញតម្រូវការភ្ញៀវទេសចរណ៍ទាំងភ្ញៀវជាតិនិងអន្តរជាតិដែលមកដើរកំសាន្តនៅខេត្តសៀមរាបដែលបង្កើតជាការងារជាច្រើន សម្រាប់ប្រជាជនដែលរស់នៅក្នុងខេត្តនេះ។ ការងារទាំងនេះមិនត្រឹមតែផ្តល់ការងារដល់ប្រជាជនក្នុងខេត្តប៉ុណ្ណោះទេ គេសង្កេតឃើញថាមានប្រជាជននៅតាមបណ្តាខេត្តផ្សេងៗ ដែលនៅជាប់នឹងខេត្តសៀមរាបក៏មករកការងារនៅក្នុងខេត្តសៀមរាបផងដែរ។ ផ្សារភ្ជាប់ជាមួយភ្ញៀវទេសចរណ៍ប្រជាជននៅតំបន់នេះបានខិតខំសិក្សាភាសាបរទេស ដើម្បីក្លាយជាមគ្គុទេសដើម្បីបង្ហាញពីប្រវត្តិសាស្ត្ររបស់ប្រាសាទនីមួយៗ។ ហើយនៅតំបន់ប្រាសាទនីមួយៗប្រជាជនបានប្រកបមុខរបរដូចជាលក់វត្ថុអនុស្សាវរីយ៍ រូបចម្លាក់ រូបគំនូរ សម្លៀកបំពាក់នៅតំបន់នោះផងដែរ។ ដោយឡែកនៅទីជនបទប្រជាជននៅខេត្តសៀមរាប ប្រកបមុខរបរកសិកម្ម ចិញ្ចឹមសត្វជាដើម។ លើសពីនេះគេក៏បានបង្កើតរមណីយដ្ឋានសិប្បនិម្មិតសម្រាប់ភ្ញៀវទេសចរណ៍សម្រាកលំហែកាយផងដែរ។

ប្រជាជនប្រមាណ ១៨% រស់នៅតាមតំបន់ជាប់បឹងទន្លេសាបផ្អែកលើអាជីវកម្មនេសាទនិងធ្វើចំការដំនាំផ្សេងៗ និង១២%ទៀតរស់នៅតាមទីប្រជុំជននិងក្រុងដែលមានមុខរបរពាណិជ្ជកម្ម និងជាមន្ត្រីរាជការ។

## ១.២ ស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្ន

តាមធម្មតាកម្មសិទ្ធិដីធ្លី ត្រូវបានគេទទួលស្គាល់តាមការចុះការចុះបញ្ជី ហើយកម្មសិទ្ធិនេះមានការប្រែប្រួលនិងវិវត្តទៅតាមការប្រែប្រួលនៃប្រវត្តិសាស្ត្រនិងបរិបទសង្គម។ ហេតុដូចនេះដើម្បីស្វែងយល់ពីស្ថានភាពទូទៅនៃការចុះបញ្ជីដីធ្លីនាពេលបច្ចុប្បន្នឱ្យកាន់ច្បាស់ យើងនឹងលើកយក២ចំនុចមកសិក្សា គឺទី១ **ការវិវត្តសិទ្ធិដីធ្លីនៅកម្ពុជា** និងទី២ **គោលគំនិតនៃការចុះបញ្ជីធ្លី។**

### ១.២.១ ការវិវត្តសិទ្ធិលើដីធ្លីនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានផ្ទៃក្រលា១៨១០៣៥គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដែលមានប្រជាជនប្រមាណ១៣លាននាក់ដែលមានការគ្រប់គ្រងដីធ្លី ទៅតាមការវិវត្តជាដំណាក់កាល។កាលពីសម័យមុនការគ្រប់គ្រងដីធ្លី គឺជាព្រះមហាក្សត្រទ្រង់ជាម្ចាស់ទាំងស្រុង ជាហេតុនាំឱ្យប្រជាជនមានការពិបាកក្នុងការកាន់កាប់ដីធ្លីហើយប្រជាជននាសម័យនោះមានចំនួនតិចហើយដីធ្លីពុំទាន់មានទីផ្សារដូចពេលបច្ចុប្បន្នទេ ជាហេតុនាំឱ្យប្រជាជនដែលធ្វើកសិកម្មបានចល័តពីកន្លែងមួយទៅកន្លែងមួយ និងអាចកាន់កាប់ដីធ្លីដោយសេរី ទោះបីជាដីនោះមិនមែនកម្មសិទ្ធិផ្ទាល់ខ្លួនក៏ដោយ។ចាប់ពីឆ្នាំ១៨០០ ដល់ ឆ្នាំ១៩៣០អាណានិគមបារាំងព្យាយាមដាក់បញ្ចូលនូវប្រព័ន្ធទ្រព្យសម្បត្តិឯកជន និងកម្មសិទ្ធិជាផ្លូវការ ទោះបីជាមិនបានសម្រេចទាំងស្រុងក៏ដោយ បារាំងបាននាំប្រព័ន្ធចូលដែលធ្វើឱ្យប្រព័ន្ធកម្មសិទ្ធិឯកជន មាននៅកម្ពុជាជាលើកដំបូង។ នៅក្រោយអាណានិគមបារាំងនេះ ចូលដល់សម័យសង្គមរាស្ត្រនិយម និង លន់ នុល ប្រទេសកម្ពុជាបានបន្តប្រើប្រាស់ប្រព័ន្ធដីធ្លីដែលបារាំងបាននាំចូលនោះ ដោយយកច្បាប់បារាំងបានចងក្រងមកប្រើប្រាស់ ដូចជាច្បាប់ការងារ ធ្វើឯកជនភាវូបនីយកម្ម និងការធ្វើពាណិជកម្មដីធ្លី។ កន្លងមកដល់សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩បានដកហូតយកទ្រព្យសម្បត្តិឯកជនទាំងអស់ដាក់ជាសម្ភាពដូចនេះការកាន់កាប់ដីធ្លីឯកជនត្រូវលុបចោល ហើយបទដ្ឋានដីធ្លីទាំងអស់ត្រូវបានរបបខ្មែរក្រហមបោះបង់ចោលទាំងស្រុង។ លុះដល់ឆ្នាំ១៩៨៩ ប្រជាជនកម្ពុជា អាចចូលកាន់កាប់ដីធ្លីឡើងវិញដោយកាន់កាប់ជាបណ្ដោះអាសន្ន ។ ដោយសារប្រទេសកម្ពុជាមានសង្គ្រាម អស់រយៈពេលយូរ ដូចនេះហើយដើម្បីធានាលើសិទ្ធិកម្មសិទ្ធិ រាជរដ្ឋាភិបាលបានចាប់ផ្ដើមឡើងវិញសារជាថ្មីទាំងធនធាន

និងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ រហូតដល់ឆ្នាំ១៩៩២ បានតាក់តែងច្បាប់ភូមិបាលឡើង។[3] សិទ្ធិលើកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់គឺចាំបាច់ណាស់ ដូចនេះយោងតាមច្បាប់ភូមិបាលឆ្នាំ១៩៩២ នេះបានធ្វើការបែងចែកទ្រព្យសម្បត្តិឯកជន និង ទ្រព្យសម្បត្តិរដ្ឋ ដោយប្រគល់ដីទៅឱ្យប្រជាជនកាន់កាប់តែកំណត់ដីលំនៅឋានទំហំត្រឹមតែ២០០០ម៉ែត្រ ដីសម្រាប់ធ្វើកសិកម្មមិនឱ្យលើសពី៥ហិចតានោះទេ។ បន្តមកដល់ឆ្នាំ២០០១ច្បាប់ភូមិបាលថ្មីមួយត្រូវបានរដ្ឋាភិបាលចេញប្រកាសឱ្យប្រើឡើងវិញ។ តាមរយៈច្បាប់នេះ បានធ្វើការកំណត់ដែលបានប្រជាជនកាលពីមុននោះជាភោគៈ ហើយអាចក្លាយជាកម្មសិទ្ធិករបាន ។[4]

## ១.៣ បទបញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលគាំទ្រដល់ដំណើរការនៃការចុះបញ្ជីដីធ្លី

បទបញ្ញត្តិនិងលិខិតបទដ្ឋាននានាដែលគាំទ្រដល់ដំណើរការនៃការចុះបញ្ជីដីធ្លីទាំងពីរប្រព័ន្ធរួមមាន៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣
- ច្បាប់ភូមិបាលឆ្នាំ ២០០១
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧អនក្រ/បក, ៣១ ឧសភា ២០០២
- អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ចុះថ្ងៃទី ៣១ ឧសភា ២០០២
- អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២
- ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី, លេខ ១១២ ដសន/ប្រក, ២១ សីហា ២០០២
- សារាចរណែស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីក្បាលដី ( ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ) លេខ ០០១ អនក្រ/បក, ១៩ សីហា ២០០២
- សារាចរណែនាំលេខ០១ ដនស/សដ ស្តីពីការអនុវត្តនីតិវិធីមានលក្ខណៈដាច់ដោយដុំ, ចុះថ្ងៃទី១៤ មិនា ២០០៤

[3] ច្បាប់ភូមិបាលកម្ពុជា និងសៀវភៅស្រាវជ្រាវ ២០០៥

[44] ច្បាប់ភូមិបាល២០០១ មាត្រា៣៨

- សេចក្តីជូនដំណឹងស្តីពីការបញ្ចប់ការចូលកាន់កាប់ភោគៈលើអចលនវត្ថុ, លេខ៤៣ សជណ/កបច ចុះថ្ងៃ០៦ កញ្ញា ២០០១

## ១.៣.១ ការចាត់ចំណាត់ថ្នាក់ដីតាមច្បាប់ភូមិបាល ២០០១

ការចាត់ចំណាត់ថ្នាក់ដីអនុលោមតាមច្បាប់ភូមិបាលកម្ពុជាឆ្នាំ២០០១ដីមាន៥ប្រភេទរួមមាន ទ្រព្យសម្បត្តិសាធារណៈរដ្ឋ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទ្រព្យសម្បត្តិឯកជន ទ្រព្យសម្បត្តិវត្ត និង ទ្រព្យរបស់ជនជាតិដើមភាគតិច។ លើសពីនេះទៅទៀត ប្រភេទដីនីមួយៗក៏បែងចែកយ៉ាងច្បាស់ អំពីអ្នកដែលអាចមានសិទ្ធិកាន់កាប់បាន[5]។ ខាងក្រោមនេះគឺការពណ៌នាអំពីប្រភេទ និងលក្ខណៈ របស់ដីតាមប្រភេទដីនីមួយៗ។

### ក. ទ្រព្យសម្បត្តិសាធារណៈរដ្ឋ

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា១៥ បានរាយនាមនូវទ្រព្យជាច្រើនដែលចាត់ទុកជា ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋរួមមានៈ

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជាព្រៃឈើ ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាននិងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយណាដែលជាកម្មវត្ថុ នៃការរៀបចំពិសេសសម្រាប់ប្រយោជន៍ទូទៅ ដូចជា តីរថាន កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់អោយប្រើប្រាស់ជាសាធារណៈតាមស្ថានភាពកំណើត ឬក្រោយពីបានរៀបចំ ដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និង ឧទ្យាន សាធារណៈ និងចំណីផ្លូវដើរ។
- ទ្រព្យទាំងឡាយណាដែលត្រូវបានដាក់អោយដំណើរការសម្រាប់សេវាសាធារណៈ ដូចជា សាលារៀន ឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ ។
- ទ្រព្យសម្បត្តិទាំងឡាយដែលបង្កើតជាដែនបម្រុងធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។ អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

[5] សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលលេខ២៧សជណ/អគ, ស្តីពីគោលនយោបាយដីធ្លី, ០១ កក្កដា ២០០៩

បន្ថែមពីនេះទៅទៀត ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចកំណត់អាជ្ញាយុកាល និង មិនអាចលក់ដូរធ្វើលទ្ធកម្មបានឡើយ[6]។

### ខ. ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋគឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលមិនស្ថិតក្នុងប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដូចដែលបានរៀបរាប់នៅក្នុងចំនុច (**ក**) ខាងលើ ។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការលក់ ជួល ប្រើប្រាស់ ធ្វើសម្បទាន និងការផ្ទេរសិទ្ធិកម្មសិទ្ធិជាដើម ។ ម្យ៉ាងវិញទៀត លក្ខខណ្ឌទាំងឡាយ និងនីតិវិធីនៃការលក់ ការគ្រប់គ្រងត្រូវកំណត់ដោយអនុក្រឹត្យ ឬតាមការកំណត់ដោយច្បាប់[7] ។

### គ. ទ្រព្យសម្បត្តិឯកជន

ទ្រព្យសម្បត្តិឯកជនគឺជាទ្រព្យសម្បត្តិទាំងឡាយណាក្រៅពីទ្រព្យសម្បត្តិរដ្ឋនិងទ្រព្យសម្បត្តិសមូហភាពហើយទ្រព្យឯកជនគឺ រាល់ដីទាំងឡាយណាដែលបានក្លាយជាទ្រព្យសម្បត្តិឯកជនដោយស្របច្បាប់ ។ កម្មសិទ្ធិរបស់បុគ្គលតែម្នាក់ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តីគឺជាកម្មសិទ្ធិឯកជន[8]។ ទ្រព្យសម្បត្តិឯកជន កម្មសិទ្ធិករម្នាក់ៗអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត[9]។

### ឃ. ទ្រព្យសម្បត្តិវត្ត

ទ្រព្យសម្បត្តិវត្តជាសំណង់ដែលមាននៅក្នុងនិងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនា។ ទ្រព្យសម្បត្តិវត្តគឺដូចគ្នាទៅនឹងទ្រព្យសម្បត្តិសាធារណៈរដ្ឋដែរ គឺមិនអាចលក់ ដូរ ឬធ្វើអំណោយហើយគ្មានអាជ្ញាយុកាលឡើយ។ មិនអាចកាន់កាប់ដោយបុគ្គលឯកជន និងមិនអាចកែប្រែអោយ**ភាគតិច**ក្លាយទៅជាកម្មសិទ្ធិឯកជនបានឡើយ[10]។

### ង. ទ្រព្យរបស់ជនជាតិដើម

សហគមន៍ជនជាតិដើមភាគតិចគឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃ ជាតិពន្ធ សង្គមវប្បធម៌ និង សេដ្ឋកិច្ច ប្រតិបត្តិតាមរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ដីសហគមន៍ជនជាតិភាគតិច គឺជាដីទាំងអស់ដែល

---

[6] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា១៦

[7] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា១៦ និង មាត្រា១៧

[8] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា១០

[9] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៣៨

[10] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា២០ និង មាត្រា២១

សហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី ។ ដីសហគមន៍ជនជាតិដើមភាគតិច គឺមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណាម្នាក់ ឬសមាជិកណាម្នាក់នោះទេ។ សរុបមក ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីរបស់ជនជាតិដើមភាគតិចទាំងមូលតែម្តង។ ដីសហគមន៍ជនជាតិដើមភាគតិចនេះ គឺត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព[11] ។

### ១.៣.២ ប្រភេទដីដែលអាចចុះបញ្ជីបាន

ដីដែលអាចចុះបញ្ជីបាន ហើយឈានដល់ការទទួលបានលទ្ធកម្មកម្មសិទ្ធិ ឬ សិទ្ធិភោគៈ៖

- អចលនវត្ថុឯកជន ឬដីឯកជន
- ដីសម្បទានសង្គមកិច្ច ដែលរដ្ឋផ្តល់ដល់ប្រជាពលរដ្ឋសម្រាប់គោលដៅសង្គមកិច្ច[12]
- កម្មសិទ្ធិលើអចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម[13]។

មានតែភោគៈដែលបានកាន់កាប់ដីត្រឹមត្រូវប៉ុណ្ណោះដែលអាចទទួលបានកម្មសិទ្ធិ។ បុគ្គលដែលជាភោគៈស្របច្បាប់ហើយបានកាន់កាប់ដីចាប់ពី៥ឆ្នាំឡើងទៅ អាចស្នើសុំចុះបញ្ជីដើម្បីទទួលបានកម្មសិទ្ធិ[14] ។

### ១.៣.៣ គោលការណ៍ដើម្បីទទួលបានកម្មសិទ្ធិដីធ្លី

របបដីធ្លីឯកជនត្រូវបានទទួលស្គាល់ឡើងវិញនាឆ្នាំ១៩៨៩ បន្ទាប់ពីត្រូវបានលុបបំបាត់ទាំងស្រុងនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ របបកម្មសិទ្ធិមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់នោះឡើយ[15] ។

មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិករលើដីនៃព្រះរាជាណាចក្រកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់ សមូហភាពដែនដីសាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ ឬសមាគមន៍កម្ពុជា សហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជាដែលទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល[16] ។

ភោគីត្រូវកាន់កាប់ដីដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋយ៉ាងតិចណាស់ប្រាំឆ្នាំតាមការកំណត់របស់ច្បាប់ទើប អាចប្រែក្លាយជាកម្មសិទ្ធិករបាន ។ គ្មានការចាប់យកដីតាមទំនើងចិត្តណាមួយអាច

[11] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា២៣ មាត្រ២៥ និង មាត្រា២៦
[12] អនុក្រឹត្យលេខ ១៩ អនក្រ/បក, ស្តីពីសម្បទានសង្គមកិច្ច, ១៩ មិនា ២០០៣
[13] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦០
[14] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា៣១
[15] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា០៧
[16] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា០៨

កើតឡើង ទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈបានឡើយ ចាប់ពីពេលច្បាប់ភូមិបាល ២០០១ ចូលជាធរមាន[17] ។ ប៉ុន្តែដីទំនេរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ អាចត្រូវបានបែងចែកទៅបុគ្គលដែលត្រូវការដីក្នុងគោលដៅសង្គមកិច្ច ដូចជាពលរដ្ឋក្រីក្រដែលគ្មានដីក្នុងការសង់លំនៅដ្ឋាន, ធ្វើកសិកម្មជាលក្ខណៈគ្រួសារ, គ្រួសារដែលផ្លាស់ប្តូរទីលំនៅបណ្តាលមកពីការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំរាប់ការតាំងទីលំនៅថ្មី, គ្រួសារដែលរងគ្រោះដោយសារគ្រោះធម្មជាតិ, គ្រួសារមាតុភូមិនិវត្តន៍, គ្រួសារយោធិនរំសាយ និងគ្រួសារយុទ្ធជនពលីពិការ, ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច, ជួយសម្រួលដល់សម្បទានដីសេដ្ឋកិច្ច ដោយ ផ្តល់ដីឡូត៍ដល់កម្មករចម្ការធំៗសម្រាប់សង់លំនៅឋាន ឬធ្វើកសិកម្មលក្ខណៈគ្រួសារ, អភិវឌ្ឍតំបន់ដែលពុំត្រូវបានអភិវឌ្ឍសមស្រប[18] ។

### ១.៣.៤ និយមន័យកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់បានកម្រិត[19] ។

កម្មសិទ្ធិ ជាសិទ្ធិពេញលេញជាម្ចាស់លើទ្រព្យ ។ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យ[20] ។

- **កម្មសិទ្ធិករ**

**កម្មសិទ្ធិករ** ជាម្ចាស់កម្មសិទ្ធិលើទ្រព្យ និងមានសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យរបស់ខ្លួន[21] ។ ឧ. បុគ្គលម្នាក់ជាម្ចាស់កម្មសិទ្ធិករលើដីមួយកន្លែង ដូចនេះគាត់អាចសង់លំនៅដ្ឋានសំរាប់ស្នាក់នៅ ( សិទ្ធិប្រើប្រាស់ ) ជួលយកកម្រៃ ( សិទ្ធិអាស្រ័យផល ) និងធ្វើប្រទានកម្មនានា ( សិទ្ធិចាត់ចែង ) តាមការចង់បានរបស់គាត់ ។ សិទ្ធិទាំងនេះមិនអាចត្រូវបានតតីយជនណាមួយមកបំពានបានឡើយ ។

កម្មសិទ្ធិករត្រូវប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវទ្រព្យរបស់ខ្លួន ជៀសវាងអំពើទាំងឡាយដែលច្បាប់បានហាមឃាត់ ដើម្បីកុំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ ឬសណ្តាប់ធ្នាប់សាធារណៈ និងប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ។ កម្មសិទ្ធិករត្រូវប្រើប្រាស់សិទ្ធិភណ្ឌិកចម្បងរបស់ខ្លួនឱ្យស្របតាមច្បាប់ ។

---

[17] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា២៩ វាក្យខណ្ឌ២

[18] អនុក្រឹត្យលេខ ១៩ អនក្រ/បក, ស្តីពីសម្បទានសង្គមកិច្ច, ១៩ មិនា ២០០៣, មាត្រា០៣

[19] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៣៨

[20] សទ្ទានុក្រម នៃច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១

[21] សទ្ទានុក្រម នៃច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១

កម្មសិទ្ធិករនៃដីត្រូវមានអានុភាពទាំងផ្នែកលើដី និងផ្នែកខាងក្រោមដី នៅក្នុងទំហំនៃការកម្រិតដែលច្បាប់ ឬបទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ ។ ក្នុងករណីនៅខាងក្រោមដីមានជាលក្ខណៈវត្ថុបុរាណបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រត្រូវចាត់ចូលជាសម្បត្តិសាធារណៈរបស់រដ្ឋ ។ កម្មសិទ្ធិករនៃដី មិនអាចប្រើប្រាស់ដីរបស់ខ្លួនក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬរំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះបានឡើយ[22]។

- **ភោគៈ និងភោគី**

**ភោគី** គឺជាអ្នកទទួលបានភោគៈ។ មានតែភោគៈត្រឹមត្រូវតាមច្បាប់កំណត់ប៉ុណ្ណោះដែលអាចនាំឱ្យបានកម្មសិទ្ធិ[23] ។

**ភោគៈ** ជាសិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយ ជាបណ្ដោះអាសន្នមិនទាន់ស៊ុបជារបស់ខ្លួនមែនទែនទេ។ ភោគៈ ជាពាក្យផ្ទុយនឹងកម្មសិទ្ធិ ដែលជាសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗលើទ្រព្យណាមួយ[24] ។ ឧ. ដីមានប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុ ជាដីកម្មសិទ្ធិ ឯដីពលរដ្ឋរស់នៅ ឬធ្វើកសិកម្មដែលមិនទាន់មានប្លង់សុរិយោដី ជាដីភោគៈ ។

បុគ្គលដែលបានកាន់កាប់ទ្រព្យសម្បត្តិដែលជាដីសាធារណៈរបស់រដ្ឋ មិនអាចទទួលបានកម្មសិទ្ធិនោះឡើយទោះបីពួកគាត់បានកាន់កាប់តាំងពីពេលណាក៏ដោយ នឹងបានបំពេញលក្ខខណ្ឌទាំង៥ នៃភោគៈក៏ដោយ។

## ១.៣.៥ គោលការណ៍នៃការកាន់កាប់ភោគៈ

ភោគីត្រូវគោរពលក្ខខណ្ឌមួយចំនួន នៃច្បាប់ដើម្បីក្លាយខ្លួនជាកម្មសិទ្ធិករស្របច្បាប់នៃដី ។

ច្បាប់ភូមិបាលឆ្នាំ២០០១មាត្រា៣៥បានចែងថាដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុលុះត្រាតែភោគៈនោះកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងលឺជាសាធារណៈ គ្មានការអាក់ខាន និងដោយសុច្ចរិត។

**ភោគីត្រូវកាន់កាប់អចលនវត្ថុដោយពិតប្រាកដ**គឺថាភោគីត្រូវកាន់កាប់ដោយខ្លួនឯងក្ដីឱ្យអ្នកដទៃធ្វើឱ្យក្ដី ត្រូវកាន់កាប់ឱ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួនក្នុងគោលដៅខ្លួនជាភោគីយ៉ាងផ្ដាច់មុខ កុំឱ្យឃើញថាការធ្វើនោះ គឺដោយសារសិទ្ធិណាមួយផ្សេងទៅវិញ។

---

[22] ក្រមរដ្ឋប្បវេណី នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៣៩

[23] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា០៦

[24] សន្ទានុក្រម នៃច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១

ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈ ដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ ។ ភោគីនោះត្រូវបានគេចាត់ទុកជាមោឃៈ។

**ភោគីកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា** គឺថាភោគីដែលបានមកដោយហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ក៏ប៉ុន្តែកាលណាបើគេប្រើហិង្សាក្នុងពេលមានតតិយជនដែលគ្មានសិទ្ធិសោះមកដណ្តើម នោះហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលបានមកដោយសន្តិភាពពីដើមមកនោះទេ ។

**ភោគីកាន់កាប់អចលនវត្ថុដោយដឹងលឺជាសាធារណៈ** គឺថាភោគីកាន់កាប់ឥតលាក់បាំង អ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះ នឹងបានដឹងលឺឃើញមិនខាន។

**ភោគីកាន់កាប់អចលនវត្ថុដោយគ្មានអាក់ខាន** គឺថាភាគីត្រូវធ្វើនូវកិច្ចការផងទាំងពួង តាមធម្មតាជាប្រក្រតី ក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ ។ ការអាក់ខានក្នុងរយៈពេលខ្លី ឬបោះបង់ចោលឱ្យនៅទំនេរដើម្បីឱ្យដីមានជីជាតិឡើងវិញ មិនមែនជាឧបសគ្គនៃលទ្ធកម្មកម្មសិទ្ធិនោះទេ ។

**ភោគីកាន់កាប់ដោយសុចរិត** គឺថាភោគីមិនដឹងពីសិទ្ធិជាយថាហេតុរបស់តតិយជន លើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។

បុគ្គលជាភោគីស្របច្បាប់ដែលបានលក្ខខណ្ឌនៃភោគៈនៃមាត្រា៣៨និងបានកាន់កាប់យ៉ាងតិចចាប់ពី៥ឆ្នាំឡើងទៅគិតមកដល់កាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមានមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ តែបើភោគីបំពេញគ្រប់លក្ខខណ្ឌនៃភោគៈហើយ តែមិនទាន់គ្រប់រយៈពេល៥ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចអាចឱ្យគាត់កាន់កាប់ឱ្យគ្រប់រយៈពេល៥ឆ្នាំដើម្បីអាចធ្វើលទ្ធកម្មកម្មសិទ្ធិ[25]។

បុគ្គលដែលកាន់កាប់ដីជារបស់រដ្ឋ ក្រោយការចូលជាធរមានរបស់ច្បាប់ភូមិបាលមិនត្រូវបានសិទ្ធិជាភោគៈ ដើម្បីទទួលបានជាកម្មសិទ្ធិនោះឡើយ។ ការចូលកាន់កាប់ត្រូវបញ្ចប់ នៅពេលច្បាប់នេះចូលជាធរមាន ។ មានតែបុគ្គលដែលទទួលបានសម្បទានសង្គមកិច្ចពីរដ្ឋតែប៉ុណ្ណោះ ដែលជាភោគីស្របច្បាប់ ។ រាល់ការចុះបញ្ជី ដីធ្លីគ្រប់ទម្រង់ទាំងអស់គឺ សុទ្ធតែមានគោលដៅក្នុងការរក្សានៅផលប្រយោជន៍សាធារណៈ និងឯកជន និងមានគោលបំណងដូចគ្នាគ្រប់ខេត្តក្រុង ដោយមានចក្ខុវិស័យតែមួយរបស់រាជរដ្ឋាភិបាល។

[25] ច្បាប់ភូមិបាល នស/រកម/០៨០១, ៣០ សីហា ២០០១, មាត្រា៣១

**ក. គោលបំណងនៃការចុះបញ្ជីដីធ្លី**

គោលបំណងនៃការចុះបញ្ជីរួមមាន៖

- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធនៃការចុះបញ្ជីចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីចំពោះប្រជាពលរដ្ឋ
- ពង្រឹងប្រសិទ្ធិភាពនៃការកាន់កាប់ដី
- ប្រតិបត្តិឱ្យបានម៉ាំមួននូវបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងដីធ្លី
- កសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីក្បាលដីឱ្យមានលក្ខណៈច្បាស់លាស់និងប្រសិទ្ធិភាពក្នុងការគ្រប់គ្រង
- រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ
- ជំរុញឱ្យមានស្ថេរភាពសង្គម និងវឌ្ឍនភាពសង្គម។

**ខ. សារៈប្រយោជន៍នៃការចុះបញ្ជីដីធ្លី**

ការចុះបញ្ជីដីធ្លីបានផ្តល់នូវសារប្រយោជន៍ជាច្រើន ដល់ប្រជាពលរដ្ឋ និងសង្គមដូចជា៖

- ធានា និងរក្សានៃភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ
- បង្កើននូវការប្រើប្រាស់ដីធ្លីឱ្យអស់ពីលទ្ធភាព
- ផ្តល់សុវត្ថិភាព និងកាត់បន្ថយទំនាស់លើការកាន់កាប់ដីធ្លី
- ធានានូវសុវត្ថិភាព និងប្រសិទ្ធិភាពនៃការផ្ទេរសិទ្ធិលើអចលនវត្ថុ
- ធ្វើឱ្យដីធ្លីមានភាពសកម្មដូចជាការបង្កបង្កើនផលជាដើម
- ធ្វើឱ្យការប្រើប្រាស់ដីធ្លីជាផលទុន សម្រួលដល់ទីផ្សារដីធ្លី
- គាំទ្រដល់ការធ្វើកំណែទម្រង់ដីធ្លីកាន់តែមានប្រសិទ្ធិភាព
- រក្សា និងគ្រប់គ្រងបានល្អនូវអចលនវត្ថុជារបស់រដ្ឋ
- ធ្វើឱ្យប្រព័ន្ធនៃការយកពន្ធលើដីធ្លីមានភាពល្អប្រសើរ
- សម្រួលដល់ការងាររៀបចំផែនការគំរោងនានា សំរាប់ការអភិវឌ្ឍន៍
- ការពារ និងគ្រប់គ្រងបរិស្ថានបានល្អ។

## ១.៤ សមត្ថកិច្ច និងភារកិច្ចរបស់អភិបាលខេត្ត ក្រុង

នៅក្នុងការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ អភិបាលរាជធានី-ខេត្ត ត្រូវលើកសំណើរពីតំបន់ដែលត្រូវវិនិច្ឆ័យទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិភាក្សា និងធ្វើការ

សម្រេចជ្រើសយកតំបន់វិនិច្ឆ័យ។ ក្រោយពីបានពិភាក្សានិងបានការយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលខេត្តក្រុងត្រូវចេញសេចក្ដីប្រកាសតំបន់ និង ព្រំប្រទល់នៃទីតាំងធ្វើការ វិនិច្ឆ័យតាមរបៀបបង្ហាញផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

អភិបាលរាជធានី ខេត្តត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធទៅអាជ្ញាធរមូលដ្ឋាន នៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងហោចណាស់ ៧ ( ប្រាំពីរ ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីប្រកាសកំណត់តំបន់វិនិច្ឆ័យ។

អភិបាលរាជធានី-ខេត្ត ត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្ដីជូនដំណឹងត្រូវបិទឱ្យសាធារណៈជនដឹងយ៉ាងហោចណាស់ ៣ ( បី ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយមើលក្នុងភូមិ ឬទីតាំងធ្វើវិនិច្ឆ័យផ្ទាល់។ សេចក្ដីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធិភាព ក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន[26] ។

**ក. សមាសភាពនៃគណៈកម្មការរដ្ឋបាល**

សមាសភាពនៃគណៈកម្មការរដ្ឋបាលនឹងត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសឡើង ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមានៈ

- តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន
- មន្ត្រីការងារគ្រប់គ្រងតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក
- អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក

[26] អនុក្រឹត្យលេខ ១២២អនក្រ/បក, ស្ដីពីការកែសម្រួលមាត្រា៦ មាត្រា ៧ និងមាត្រា១១ នៃអនុក្រឹតលេខ ៥៦ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ៩ មិថុនា ២០១៦, មាត្រា១

**ខ. ភារកិច្ចរបស់គណៈកម្មការរដ្ឋបាល**

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមានៈ

- បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី
- ទទួលរាល់ពាក្យបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
- លើកសំណើរផ្តល់សិទ្ធិលើដីធ្លីជូនអ្នកកាន់កាប់ដី ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ[27] ។

[27] អនុក្រឹត្យលេខ ៤៦អនប្រ/បក, ស្តីពីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីក្បាលដី, ៣១ ឧសភា ២០០២, មាត្រា២

# ជំពូកទី ២ អំពីការចុះបញ្ជីដីធ្លីក្នុងខេត្តសៀមរាប

## ២.១ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

### ២.១.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

នៅក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានគេបែងចែកជាប្រាំដំណាក់កាលដែលរួមមាន៖

- ដំណាក់កាលទី ១ អំពីការត្រៀមរៀបចំ
- ដំណាក់កាលទី ២ អំពីប្រតិបត្តិការបច្ចេកទេស
- ដំណាក់កាលទី ៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- ដំណាក់កាលទី ៤ អំពីការសម្រេចលើឯកសារ
- ដំណាក់កាលទី ៥ អំពីការចេញប័ណ្ណ

#### ២.២.១.១ ដំណាក់កាលស្តីពីការរៀបចំ

បន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការរៀបចំរួចមក អភិបាលខេត្តក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់វិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពណ៌នា ឬតាមរបៀបទាំងពីរ។

នៅពេលតំបន់វិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមានមន្ត្រីកំណត់ព្រំដីមន្ត្រីវាស់វែង មន្ត្រីវិនិច្ឆ័យឱ្យទៅបំពេញភារកិច្ចក្នុងតំបន់វិនិច្ឆ័យនោះ។ ទន្ទឹមនឹងនេះមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងពាក់ព័ន្ធនឹងតំបន់វិនិច្ឆ័យ ក៏ត្រូវចាត់តាំងមន្ត្រីម្នាក់ឱ្យ ទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីជូនអភិបាលខេត្ត ក្រុងដើម្បីបញ្ចូលជាសមាជិកនៃគណៈកម្មការរដ្ឋបាលផងដែរ។

យោងតាមចំណាត់តាំងខាងលើ អភិបាលខេត្ត ក្រុងត្រូវបង្កើតគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវវិនិច្ឆ័យ ទៅតាមសមាសភាពដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៤៦ ស្តីពីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីក្បាលដី។

គណៈកម្មការរដ្ឋបាលត្រូវរៀបចំប្រជុំណែនាំសមាជិករបស់ខ្លួនឱ្យយល់អំពីកិច្ចដំណើរការនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ កំណត់បែងចែកភារកិច្ចដល់សមាជិកម្នាក់ៗ រៀបចំផែនការសម្រាប់អនុវត្ត និងលើកសំណើរទៅអភិបាលខេត្ត ក្រុងអំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសតំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ ។

អភិបាលត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ មានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរ មូលដ្ឋាននៃតំបន់វិនិច្ឆ័យ យ៉ាងហោចណាស់ ១៥ថ្ងៃមុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ។ អភិបាលខេត្តត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំតាមរយៈការបិទផ្សាយ និងតាមឧគ្ឃោសនសព្ទ ដល់សាធារណៈជនយ៉ាងហោចណាស់ប្រាំពីរថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយនៅទីកន្លែងដែលងាយឃើញនៅក្នុងភូមិ ឬទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ គោលបំណងនៃការផ្សព្វផ្សាយនេះគឺដើម្បីឱ្យកម្មសិទ្ធិករ និងអ្នកកាន់កាប់ដី ព្រមទាំងអ្នកពាក់ព័ន្ធនិងក្បាលដីក្នុងតំបន់វិនិច្ឆ័យបានយល់ពីកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញតាមរយៈការផ្តល់ជាពត៌មានឯកសារនិងភស្តុតាងសំខាន់ៗទាក់ទងនិងអត្តសញ្ញាណដី និងអត្តសញ្ញាណនៃម្ចាស់ដី ដែលធ្វើទិន្នន័យដែលប្រមូលបានមានភាពប្រាកដប្រជា និង សុក្រឹត ។ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬគណៈកម្មការរដ្ឋបាលត្រូវពន្យល់ប្រជាពលរដ្ឋអំពីដំណើរការនៃនីតិវិធី និងសារៈសំខាន់ដែលពួកគាត់ទទួលបាន ព្រមទាំងបំភ្លឺរាល់ចម្ងល់ដែលបានសាកសួរនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយ នោះ។ កិច្ចប្រជុំនេះត្រូវធ្វើឡើងក្នុងទីកន្លែងណាមួយនៃតំបន់វិនិច្ឆ័យ ដែលមានជាអាទិ៍ដូចជា សាលារៀន វត្តអារាមទីសាធារណៈ សាលាឃុំ សង្កាត់ សាលាស្រុក-ខណ្ឌដោយយោងតាមស្ថានភាពជាក់ស្តែង[28]

### ២.១.១.២ ដំណាក់កាលប្រតិបត្តិការបច្ចេកទេស

ក្នុងដំណាក់កាលនេះការងារនៃការវិនិច្ឆ័យត្រូវបានបែងចែកជា ២ផ្នែកសំខាន់ៗគឺ ការងារនៅទីវាល និងការងារនៅការិយាល័យ។

#### ក. ការងារនៅទីវាល

ការងារនេះស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ។ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដោយមានការសហការពីមន្ត្រីនៅមូលដ្ឋាន ( មេភូមិ មេឃុំ ចៅសង្កាត់ ) ។

- **មន្ត្រីកំណត់ព្រំដី**

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់វិនិច្ឆ័យពេលវេលា និងទីកន្លែងដែលចាប់ផ្តើមនឹងធ្វើការវិនិច្ឆ័យឱ្យបានមុន ៣ថ្ងៃយ៉ាងតិច ។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីជូនដំណឹង ។

[28] សារាចរណែនាំលេខ ០០១ដនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

ក្នុងរយៈពេលនៃការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក. បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំប្រទល់មានវត្តមានហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវកំណត់យោងតាមការព្រមព្រៀង ។

ខ. បើការព្រមព្រៀងតាមចំណុច ( ក ) ខាងលើមិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់ក្បាលដីដែលនៅជាប់ព្រំប្រទល់អវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរួមជាលាយលក្ខណ៍អក្សរ ឬជាចម្លើយផ្ទាល់មាត់ទាក់ទងនិងព្រំដី ។

គ. ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់នៃដីត្រូវអនុលោមតាមចំណុច ( ក ) ឬ ( ខ ) នៃកថាខណ្ឌទី ២ មាត្រា ៧ថ្មី នៃអនុក្រឹត្យនេះ ។

ឃ. វិវាទទាំងអស់អំពីព្រំដីដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួលតាមមាត្រា ១២នៃអនុក្រឹត្យនេះ ( អនុក្រឹត្យលេខ ៥៦ )[29] ។

- **មន្ត្រីវាស់វែង**

បន្ទាប់ពីកំណត់ព្រំដីរួច មន្ត្រីវាស់វែងត្រូវកំណត់ការងារវាស់វែង ដែលជាតម្រូវការក្នុងការកសាងប្លង់សុរិយោដី និងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ ។

- **មន្ត្រីវិនិច្ឆ័យ**

មានសិទ្ធិសាកសួរពត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ ។ មន្ត្រីវិនិច្ឆ័យអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់ចម្លើយ ដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗដែលពាក់ព័ន្ធនឹងការវិនិច្ឆ័យ ។ ប្រមូលរាល់ឯកសារ ភស្តុតាង និងពត៌មានផ្សេងៗទាក់ទងក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដីផ្តិតមេដៃ ហើយមន្ត្រីនោះត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ។ ករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្បាលដី មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីមានទំនាស់[30] ។

[29] អនុក្រឹត្យលេខ ១២២អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៦ មាត្រា ៧ និងមាត្រា១១ នៃអនុក្រឹតលេខ ៥៦ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ២០១៦, មាត្រា១

[30] សារាចរណែនាំលេខ ០០១ដនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

❖ អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ ឬអ្នកតំណាងស្របច្បាប់

អ្នកទាំងនេះមានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ តាម រយៈការផ្តល់ពត៌មានពិត ដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗទាក់ទង និងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនឈរឈ្មោះជាតំណាង ឬក្បាលដីអ្នកជាប់ព្រំដល់អ្នក ជំនាញ ។ ក្នុងពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ ពួកគាត់អាចមានសិទ្ធិជំទាស់ តវ៉ាប្រសិនបើខ្លួន យល់ថា ទិន្នន័យដែលមន្ត្រីបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យមិនត្រឹមត្រូវ ឬ ខុសពីចម្លើយរបស់ខ្លួន[31] ។

❖ អំពីភារកិច្ចរបស់អាជ្ញាធរដែនដី

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណៈសម្បត្តិងាយស្រួល សហការឱ្យបានល្អ និង ផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការទាំងឡាយមានប្រតិបត្តិការបច្ចេកទេស រដ្ឋបាលគតិយុត្តដើម្បីធ្វើ ឱ្យសម្រេចនូវការអនុវត្តនីតិវិធីដែលប្រព្រឹត្តនៅក្នុងដែនដី ដែលខ្លួនទទួលខុសត្រូវ ។ ក្នុងរយៈពេល នៃការបិទផ្សាយជាសាធារណៈនូវឯកសារដែលមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងឃុំ សង្កាត់ណាមួយ ឬតំណាងស្របច្បាប់របស់ខ្លួនត្រូវមានវត្តមានតាមកាលកំណត់ និងតាមតម្រូវការ ជាក់ស្តែងនៃការងារ[32] ។

**ខ. ការងារនៅការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាល ត្រូវបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ។

### ២.១.១.៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

អភិបាលរាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ នូវប្លង់ សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី តាមសំណើរបស់គណៈកម្មការរដ្ឋបាល ។ ការជូនដំណឹងអាចធ្វើ ឡើងតាមគ្រប់មធ្យោបាយ ដូចជា តាមរយៈការប្រជុំ វិទ្យុ ទូរទស្សន៍ សារពត៌មាន រូបភាពបិទផ្សាយ ឬតាមឧគ្ឃោសនសព្ទ. . .។ល។ ការបិទផ្សាយជាសាធារណៈមានរយៈពេល ១៥ ថ្ងៃ[33] ហើយត្រូវធ្វើ

[31] សារាចរណែនាំលេខ ០០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

[32] សារាចរណែនាំលេខ ០០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

[33] អនុក្រឹត្យលេខ ១២២អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៦ មាត្រា ៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៥៦ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ៩ មិថុនា ២០១៦, មាត្រា ១

នៅកន្លែងដែលងាយមើលឃើញ ក្នុងទីតាំងនៃតំបន់ធ្វើការវិនិច្ឆ័យ ដូចជាទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ-សង្កាត់ សាលាស្រុក...។

ក្នុងអំឡុងពេលបិទផ្សាយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវណែនាំមន្ត្រី ដែលទទួលខុសត្រូវការងារជំនាញនីមួយៗ ឱ្យប្រចាំការ នៅកន្លែងបិទផ្សាយរៀងរាល់ថ្ងៃ ទាំងថ្ងៃឈប់សំរាក ទាំងថ្ងៃបុណ្យផ្សេងៗ ដើម្បីរង់ចាំពន្យល់ ឬបំភ្លឺអំពីខ្លឹមសារនៃទិន្នន័យបកស្រាយ ចម្ងល់ផ្សេងៗដែលទាក់ទងនឹងឯកសារដែលបានបិទផ្សាយ ។ ទន្ទឹមនឹងនេះ គណៈកម្មការរដ្ឋបាលក៏ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីនៅមូលដ្ឋានចាំបាច់ជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬតំណាងផ្លូវច្បាប់របស់ជននេះ ឱ្យមកប្រចាំការរងចាំទទួលបណ្ដឹងជំទាស់ ឬបណ្ដឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាតាមគោលការណ៍កំណត់។

សាមុីអ្នកកាន់កាប់ដី ឬតំណាងស្របច្បាប់របស់ជននេះដែលមិនទាន់យល់ស្របតាមការសម្រេចបណ្ដោះអាសន្នរបស់មន្ត្រីជំនាញនៅពេលប្រតិបត្តិការកំណត់ព្រំដី ឬវិនិច្ឆ័យមានសិទ្ធិប្ដឹងជំទាស់ ឬប្ដឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅអំឡុងពេលបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ ដើម្បីឱ្យគណៈកម្មការលើកយកមកដោះស្រាយឡើងវិញ ។ ករណីមិនអាចដោះស្រាយបាន គណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅ គណៈកម្មការសុរិយោដីធ្វើការដោះស្រាយបន្ត ។ បណ្ដឹងនីមួយៗត្រូវបានកត់ត្រាដោយឡែកពីគ្នា ហើយត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកម្មវត្ថុនៃបណ្ដឹង ឈ្មោះ និងស្នាមមេដៃម្ចាស់បណ្ដឹង ឈ្មោះ និងហត្ថលេខាមន្ត្រីទទួលកត់ត្រា និងមានបញ្ជាក់ការដឹងលឺពីមេឃុំ ចៅសង្កាត់ ឬតំណាងស្របច្បាប់របស់ជននេះ ។ ករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រានោះ ត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បាន លើកលែងចំពោះករណីដែលសាមុីអ្នកកាន់កាប់ដី ឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពីមូលហេតុដែលមិនបានធ្វើការជំទាស់ ឬតវ៉ាក្នុងអំឡុងពេលនៃការបិទផ្សាយនោះ សាមុីជនអាចដាក់ពាក្យបណ្ដឹងទៅគណៈកម្មការសុរិយោដីដើម្បីដោះស្រាយតាមនីតិវិធីដែលបានកំណត់ ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិកែតម្រូវចំពោះកំហុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍អ្នកដទៃ។ ចំពោះការកែតម្រូវណាដែលនាំឱ្យជះឥទ្ធិពលដល់ប្រយោជន៍អ្នកដទៃអាចធ្វើការកែតម្រូវបាន លុះត្រាតែមានការយល់ព្រមពីជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនោះ[34] ។

[34] សារាចរណែនាំលេខ ០០១ជនស/សជ, ស្ដីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

### ២.១.១.៤ អំពីការសម្រេចលើឯកសារ

ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យគណៈកម្មការរដ្ឋបាលត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារខាងក្រោម៖

ក. លទ្ធផលដែលសម្រេចបាន

- ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ
- ចំនួនក្បាលដីដែលមិនត្រូវបានចេញប័ណ្ណជូន ដោយការកាន់កាប់ដីរដ្ឋចាប់ផ្តើមក្រោយការចូលជាធរមាននៃច្បាប់ភូមិបាល
- ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ
- ចំនួនក្បាលដីដែលមានវិវាទ
- ចំនួនក្បាលដីមានវិវាទ ដែលគណៈកម្មការរដ្ឋបាលបានដោះស្រាយរួចតាមការព្រមព្រៀង
- ចំនួនក្បាលដីមានវិវាទ ហើយបញ្ជូនទៅគណៈកម្មការសុរិយោដី
- ចំនួនក្បាលដីដែលកំពុងមានបណ្តឹងនៅតុលាការ

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវរៀបចំទម្រង់របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

ខ. ធ្វើការវាយតម្លៃលើកសំណើផ្តល់កម្មសិទ្ធិលើដី ឬអចលនវត្ថុតាមប្រភេទកម្មសិទ្ធិ ភោគៈសម្បទាន ឬរក្សាទុកជាដីរដ្ឋជូនកម្មសិទ្ធិករ ភោគី ឬអ្នកកាន់កាប់ ដោយយោងទៅតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងឯកសារ ឬភស្តុតាងដែលប្រមូលបាន ។

ក្រោយពីប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវបានកែប្រែរួចហើយ៖

- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី
- ប្រធានគណៈកម្មការរដ្ឋបាលត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវចុះហត្ថលេខាបំពេញលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យត្រង់ចំណុចហត្ថលេខាអភិបាលខេត្ត-ក្រុង ។

- អភិបាលខេត្ត-ក្រុងត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និង របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ។ ករណីមិនឯកភាពត្រូវបញ្ជាក់ពីលទ្ធផល ឱ្យបានច្បាស់លាស់ ។
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាសម្រេចជាផ្លូវ ការលើ ប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការ វិនិច្ឆ័យ ។

ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចុះហត្ថលេខាសម្រេចយល់ព្រមរួចហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ និងត្រូវបានចាត់ទុកជាឯកសារផ្លូវការតាមច្បាប់ចំពោះក្បាលដីមិនទាក់ទងវិវាទ។ចំពោះក្បាលដីដែលមានវិវាទដែលមិនទាន់ដោះស្រាយរួចជាស្ថាពរត្រូវបន្តការដោះស្រាយនៅគណៈកម្មការសុរិយោដី ឬតុលា ការ[35] ។

### ២.១.១.៥ អំពីការចេញប័ណ្ណ

នៅពេលនីតិវិធីនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និងឯកសារណបទាំងអស់ ត្រូវបានបញ្ជូនទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដើម្បីចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវត្រូវបានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណងបានធ្វើប្រតិភូកម្មក្នុងការចេញប័ណ្ណកម្មសិទ្ធិ និងប័ណ្ណភោគៈជាស្ថាពរនៅថ្ងៃ ១២ សីហា ២០០២ ។

គោលការណ៍នៃការចេញប័ណ្ណ៖

- ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិ ) ចំពោះក្បាលដី ឬ អចលនវត្ថុដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំ យ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល ( មាត្រា ៣០ វាក្យខណ្ឌទី ១ នៃច្បាប់ភូមិបាល ) ។
- ចេញប័ណ្ណសម្គាស់ម្ចាស់សិទ្ធិកាន់កាប់អចលនវត្ថុ ( ប័ណ្ណភោគៈ ) ចំពោះក្បាលដី ឬ អចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈ ពេលតិចជាង ៥ឆ្នាំមុនការចូលជាធរមាននៃច្បាប់ភូមិបាល ។ ប័ណ្ណប្រភេទនេះអាច ប្តូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅពេលរយៈពេលនៃការកាន់កាប់ដី បានគ្រប់ប្រាំឆ្នាំ ឬលើស ។

[35] សារាចរណែនាំលេខ ០០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

- អាចចេញប័ណ្ណជូនចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ ។
- ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាង ។ ការប្រគល់ប័ណ្ណត្រូវប្រគល់នៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មិនត្រូវបានប្រគល់ជូនជនក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលេង ម្ចាស់សិទ្ធិទទួលមរណៈភាព អវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាពដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស។ ករណីពិសេសនិងចាំបាច់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបាន តែត្រូវបញ្ជាក់ពីហេតុដែលមិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឱ្យប្រគល់នៅគេហដ្ឋានរបស់កម្មសិទ្ធិករ ភោគី ដោយមន្ត្រីសុរិយោដីយ៉ាងតិចពីរនាក់ ។
- នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុជូនមន្ត្រីសុរិយោដីប្រសិនបើមាន ។
- ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត ។ ចំពោះដីសម្បហាភាព ដូចជាវត្ត ឬសហគមន៍ជនជាតិដើមភាគតិច ក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះវត្ត ឬសហគមន៍ផងដែរមិនអាចចុះឈ្មោះអ្នកតំណាងឡើយ[36] ។

**❖ សោហ៊ុយសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ**

តាមរយៈប្រកាសរួមលេខ ៦៨៩ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សោហ៊ុយសេវានៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធត្រូវបានកំណត់ដូចខាងក្រោម៖

| I. សេវាសុរិយោដី និងភូមិសាស្ត្រ |
| --- |
| ( ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈជាប្រព័ន្ធក្នុង ១ម$^២$ ) |

[36] សារាចរណែនាំលេខ ០០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ១៩ សីហា ២០០២

| លរ. | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរិមានៃការផ្តល់សេវា | សុពលភាព (អចិន្ត្រៃយ៍) | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ២៧២ | ដីផលិតកម្មកសិកម្មក្រៅពីរាជធានីភ្នំពេញ | ១ | ១០០ ថ្ងៃ | | ១០០រៀលសំរាប់ដីតូចជាង ១០០ម$^{២}$ |
| ២៧៣ | ដីលំនៅដ្ឋាន ឬដីសាងសង់នៅជនបទ | ១០ | ១០០ ថ្ងៃ | | |
| ២៧៤ | ដីលំនៅដ្ឋាន ឬដីសាងសងក្នុងទីប្រជុំជនស្រុក | ២០ | ១០០ ថ្ងៃ | | |
| ២៧៥ | ដីលំនៅដ្ឋាន ឬដីសាងសងក្នុងទីប្រជុំជនក្រុង | ២៥០ | ១០០ ថ្ងៃ | | |
| ២៧៦ | ដីផលិតកម្ម កសិកម្មនៅរាជធានីភ្នំពេញ | ២៥០ | ១០០ ថ្ងៃ | | |
| ២៧៧ | ដីលំនៅដ្ឋាន ឬដីសាងសង់ក្នុងរាជធានីភ្នំពេញ | ៥០០ | ១០០ ថ្ងៃ | | |

### ២.១.២ សមិទ្ធិផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធការខារដ្ឋបាលដីធ្លី

ឆ្នាំ២០១៤បានចែកប័ណ្ណដល់ប្រជាពលរដ្ឋរួមមានចំនួន ៣.៥១១ប័ណ្ណ ( គិតតាំងពីចាប់ផ្តើមក្នុងខែ កក្កដាឆ្នាំ២០១២ ដល់ខែធ្នូ ឆ្នាំ ២០១៤ ចំនួន ៩.៥៩២ប័ណ្ណ )និងកំពុងដំណើរការអនុវត្តក្នុងភូមិចំនួន១២ ( សរុបតាំងពីចាប់ផ្តើមអនុវត្តមាន៥០ភូមិ ) ក្នុងឃុំសង្កាត់ចំនួន ០២ ( សរុបតាំងពីចាប់ផ្តើមអនុវត្តមាន ០៥ ឃុំ សង្កាត់ ) ក្នុងក្រុង ស្រុក ចំនួន ០១ ( សរុបតាំងពីចាប់ផ្តើមអនុវត្ត ០១ ក្រុងស្រុក) ក្នុងខេត្ត។

បានបញ្ចូលទិន្នន័យក្បាលដីសម្រេចបាន ៤.៣៥៦ ក្បាលដី បិទផ្សាយជាសាធារណៈបាន ៦.២១៤ ក្បាលដីនិងបានចែកប័ណ្ណដល់ប្រជាពលរដ្ឋចំនួន ១.០៧៩ ក្បាលដី។សរុបតាំងពីចាប់ផ្តើម

អនុវត្តមកបញ្ចូលទិន្នន័យបាន ៤២.៦២១ ក្បាលដី ក្នុងនោះបានចែកប័ណ្ណជូនប្រជាពលរដ្ឋរួចបាន ២៧.០៥៤ ប័ណ្ណ ។

ឆ្នាំ២០១៥បានចែកប័ណ្ណដល់ប្រជាពលរដ្ឋរួមមានចំនួន ៤.៤៩១ ប័ណ្ណ ( គិតតាំងពីចាប់ផ្ដើមក្នុងខែ កក្កដាឆ្នាំ២០១២ ដល់ឆ្នាំ ២០១៥ ចំនួន ១៣.៩១ប័ណ្ណ )បានបញ្ចូលទិន្នន័យក្បាលដីសម្រេចបាន ៧.៥៧១ ក្បាលដី បិទផ្សាយជាសាធារណៈបាន ៣.៥០០ ក្បាលដីនិងបានចែកប័ណ្ណដល់ប្រជាពលរដ្ឋចំនួន ១.៣០៤ ក្បាលដី។សរុបតាំងពីចាប់ផ្តើមអនុវត្តមកបញ្ចូលទិន្នន័យបាន ៥០.៩០២ ក្បាលដី ក្នុងនោះបានចែកប័ណ្ណជូនប្រជាពលរដ្ឋរួចបាន ២៨.៨២៩ ប័ណ្ណ

ឆ្នាំ២០១៦បានចែកប័ណ្ណដល់ប្រជាពលរដ្ឋរួមមានចំនួន ៣១២ ប័ណ្ណ ( គិតតាំងពីចាប់ផ្ដើមក្នុងខែ កក្កដាឆ្នាំ២០១២ ដល់ឆ្នាំ ២០១៦ ចំនួន ១៤.២២៥ ប័ណ្ណ )បានបញ្ចូលទិន្នន័យក្បាលដីសម្រេចបាន ៨.៧៦៧ ក្បាលដី បិទផ្សាយជាសាធារណៈបាន ១១.៥០៩ ក្បាលដីនិងបានចែកប័ណ្ណដល់ប្រជាពលរដ្ឋចំនួន ៨.០២៩ ក្បាលដី។សរុបតាំងពីចាប់ផ្តើមអនុវត្តមកបញ្ចូលទិន្នន័យបាន ៦០.៥២៦ ក្បាលដី ក្នុងនោះបានចែកប័ណ្ណជូនប្រជាពលរដ្ឋរួចបាន ៣៧.០៩០ ប័ណ្ណ ។

ឆ្នាំ២០១៧បានចែកប័ណ្ណដល់ប្រជាពលរដ្ឋរួមមានចំនួន ៦០៦ ប័ណ្ណ ( គិតតាំងពីចាប់ផ្ដើមក្នុងខែ កក្កដាឆ្នាំ២០១២ ដល់ឆ្នាំ ២០១៧ ចំនួន ១៤.៨៣១ ប័ណ្ណ )បានបញ្ចូលទិន្នន័យក្បាលដីសម្រេចបាន ៧.៩៥៩ ក្បាលដី បិទផ្សាយជាសាធារណៈបាន ១.១៧៧ ក្បាលដីនិងបានចែកប័ណ្ណដល់ប្រជាពលរដ្ឋចំនួន ៦.៣៩៩ ក្បាលដី។សរុបតាំងពីចាប់ផ្តើមអនុវត្តមកបញ្ចូលទិន្នន័យបាន ៦៩.០១៣ ក្បាលដី ក្នុងនោះបានចែកប័ណ្ណជូនប្រជាពលរដ្ឋរួចបាន ៥៥.៧២២ ប័ណ្ណ។

ឆ្នាំ២០១៨បានចែកប័ណ្ណបានចំនួន ៨៤ ប័ណ្ណ។ក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមានចំនួន ៣ក្រុម ក្រុមទី១ មានសមាជិក ១៣នាក់, ក្រុមទី២ មានសមាជិក ១៥ នាក់ (ស្រី ០១នាក់) និងក្រុមទី ៣ មានសមាជិក ១៤ នាក់ (ស្រី០១នាក់) សកម្មភាពគិតចាប់ពី ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៨ ជាលទ្ធផលសម្រេចបានមានដូចខាងក្រោម ៖

ខ.១.ផ្ទៃដីពាក់ព័ន្ធក្រុង/ស្រុក ក្រុងសៀមរាប និង ស្រុកប្រាសាទបាគង

❖ ពាក់ព័ន្ធឃុំ/សង្កាត់មាន:

- សង្កាត់សៀមរាប សង្កាត់សាលាកំរើក សង្កាត់ជ្រាវ សង្កាត់ស្លក្រាម សង្កាត់គោចក សង្កាត់សំបួរ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប៖

-សង្កាត់សៀមរាបមាន: ភូមិអារញ្ញ

-សង្កាត់សាលាកំរើក: ភូមិវត្តបូព៌

-សង្កាត់ជ្រាវ: ភូមិខ្នារ

-សង្កាត់ស្លក្រាម: ភូមិបន្ទាយចាស់ ភូមិចុងកៅស៊ូ និង ភូមិធ្លកអណ្តូង

-សង្កាត់គោចកមាន: ភូមិត្រពាំងសេះ ភូមិទក្សិណត្បូង និង ភូមិវាល

-សង្កាត់សំបួរ:ភូមិសំបួរ ភូមិតាគង់ ភូមិញ៉ៅ ភូមិវាល និង ភូមិជ្រៃ

-សង្កាត់ស្រង៉ែមាន: ភូមិកសិកម្ម ភូមិរកាធំ ភូមិព្រៃធំ ភូមិស្រង៉ែ ភូមិថ្នល់ និង ភូមិចន្លោង។

❖ លទ្ធផលដែលសម្រេចបាន

| | |
|---|---|
| ១.ប្រកាសតំបន់វិនិច្ឆ័យ (ភូមិ) | : ០៤ ភូមិ |
| ២.វាស់វែង (គិតតាមការបំពេញទិន្នន័យក្បាលដី) | : ៣៩៩៦ក្បាលដី |
| ៣.ទំហំសរុបទម្រង់បែបបទ | : ២.៥៥៤.៩២៩ ហិកតា |
| ៤.បំពេញទម្រង់បែបបទ | : ៦.៧២២ក្បាលដី |
| ៥.បញ្ចូលទិន្នន័យ | : ៦.៧២២ក្បាលដី |
| ៦.គូសក្បាលដី | : ៣.៦៧៤ក្បាលដី |
| ៧.ចេញប័ណ្ណ | : ៦.៩៦៥ប័ណ្ណ |

-បានបញ្ចប់ការវាស់វែង នៅភូមិខ្នារ សង្កាត់ជ្រាវ ភូមិត្រពាំងសេះ ភូមិទក្សិណត្បូង និង ភូមិវាល សង្កាត់គោកចក ភូមិបន្ទាយចាស់ ភូមិចុងកៅស៊ូ ភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ភូមិតាគង់ ភូមិសំបួរ ភូមិញ៉ៅ សង្កាត់សំបួរ។

-កំពុងសម្អាតទិន្នន័យនៅភូមិចំនួន ០៣ គឺ ភូមិចុងកៅស៊ូ ភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម និង ភូមិតាគង់ សង្កាត់សំបួរ ដើម្បីបិទផ្សាយ។

-បានចែកប័ណ្ណចំនួន ០៧ ភូមិគឺ ភូមិអារញ្ញ សង្កាត់សៀមរាប ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ភូមិខ្នារ សង្កាត់ជ្រាវ ភូមិត្រពាំងសេះ ភូមិទក្សិណត្បូង ភូមិវាល សង្កាត់គោចក និង ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម។

-កំពុងបិទផ្សាយភូមិចំនួនគឺ ០០ភូមិ។

គ.ការចុះបញ្ជីជួលរយៈពេលវែង

-បានចុះបញ្ជីជួលរយៈពេលវែងបានចំនួន ០៣ ក្បាលដី។

ឃ.ការងារចុះបញ្ជីពីរដ្ឋ

-បានចុះបញ្ជីដីរដ្ឋបានចំនួន ០៨ ក្បាលដី។

## ២.១.៣ បញ្ហាប្រឈម

នៅក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងខេត្តតាកែវបានពើបប្រទះនឹងបញ្ហាជាច្រើន ដែលបានធ្វើឱ្យរាំងស្ទះដល់ការដំណើរការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធនេះ ដោយបញ្ហាទាំងនោះរួមមាន៖

- មានការលំបាកក្នុងការកំណត់ព្រំដីសាធារណៈដូចជាបឹង អូរ ប្រលាយ ផ្លូវ ដោយស្ថាប័នជំនាញពាក់ព័ន្ធមិនសូវចូលរួមកំណត់ព្រំ ទំហំដី ដែលស្ថិតនៅសមត្ថកិច្ចខ្លួនផ្ទាល់ ។
- ម្ចាស់ដីធ្វើចំណាកស្រុកដែលក្បាលដីទាំងនោះមិនអាចចុះបញ្ជីបាន ។
- ក្បាលដីស្ទើរតែ ៩០% គ្មានបង្គោលព្រំ ពេលមន្ត្រីចុះទៅដល់ក៏ចាប់ជជែកឈ្លោះនាំឱ្យខាតពេល ។
- មធ្យោបាយធ្វើដំណើរ និងសម្ភារៈឧបករណ៍មានសភាពចាស់ទ្រុឌទ្រោមខ្លាំង ។
- ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យដីធ្លី ជាពិសេសទាក់ទងនិងការអនុវត្តនីតិវិធីថ្មី មិនទាន់បានទូលំទូលាយ ។
- បរិមាណនៃឯកសារចុះបញ្ជីដីធ្លីកើនឡើងជាលំដាប់ ធ្វើឱ្យកន្លែងទុកដាក់ ជួបការលំបាក
- មានការរំលោភយកដីសាធារណៈរបស់រដ្ឋពីសំណាក់ប្រជាពលរដ្ឋរួចទាមទារឱ្យមន្ទីរចេញប័ណ្ណជូនពួកគាត់ ។
- រាល់ពេលមានវិវាទគូភាគីមិនសូវមានឆន្ទៈក្នុងការសម្រុះសម្រួលចង់ឈ្នះតែរៀងៗខ្លួន ។
- ការបញ្ជាក់ការកាន់កាប់ពីអាជ្ញាធរភូមិ ឃុំ ច្រើនតែជាន់គ្នា និងមិនបញ្ជាក់តែម្តង[37] ។

## ២.២ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ បានចាប់ផ្តើមពីឆ្នាំ១៩៨៩ តាមរយៈការប្រកាសឱ្យដាក់ពាក្យសុំកាន់កាប់ដី នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៨៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩០[38]។

ដូចនេះ តើការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ជាការចុះបញ្ជីដីធ្លីយ៉ាងដូចម្តេច?

**ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ** ជាការចុះបញ្ជីដីនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ[39]។ សរុបមក ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំនេះគឺជា ការចុះបញ្ជីដីតាមរយៈការស្ម័គ្រចិត្តរបស់សាមុីខ្លួន ( ម្ចាស់កម្មសិទ្ធិ ) អោយត្រឹមត្រូវតាមច្បាប់។

[38] សាស្ត្រាចារ្យ ហាប់ ផល្លី, "នីតិទ្រព្យសម្បត្តិ" ២០១៥

[39] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៣១ ឧសភា ២០០២, មាត្រា១

## ២.២.១ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

បច្ចុប្បន្ននេះ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ អនុលោមតាម អនុក្រឹត្យលេខ៤៨ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលមាន ៥ដំណាក់កាល។

- ដំណាក់កាលទី ១ អំពីការដាក់ពាក្យស្នើសុំចុះបញ្ជី
- ដំណាក់កាលទី ២ អំពីប្រតិបត្តិការបច្ចេកទេស
- ដំណាក់កាលទី ៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- ដំណាក់កាលទី ៤ អំពីការសម្រេចលើឯកសារ
- ដំណាក់កាលទី ៥ អំពីការចេញប័ណ្ណ

### ២.២.១.១ ការដាក់ពាក្យស្នើសុំចុះបញ្ជី

ដំណាក់កាលទី១ គឺជាដំណាក់កាលដែលដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លី។ ពាក្យស្នើសុំចុះបញ្ជីដីធ្លីនេះដាក់តាមរយៈមេឃុំ ឬចៅសង្កាត់ ហើយត្រូវមានឯកសារសិទ្ធិលើក្បាលដី និងភស្តុតាងផ្សេងៗ ។

សាមុីអ្នកកាន់កាប់ដីដែលស្នើសុំចុះបញ្ជីដី ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីតាមគំរូដែលបានកំណត់មករបស់រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ[40]។

ពាក្យស្នើសុំត្រូវមានៈ

- ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យ
- ការពិពណ៌នាលំអិតអំពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ
- ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី
- ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី

មេឃុំ-ចៅសង្កាត់ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឱ្យសាមុីអ្នកកាន់កាប់ដីបំពេញបានគ្រប់គ្រាន់តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្ដីដែលសាមុីអ្នកស្នើសុំបានបំពេញនោះស្របតាមហេតុការណ៍ដែលបានកើតឡើងជាក់ស្ដែងដែរឬទេ? ចំណុចដែលត្រូវយកចិត្តទុកដាក់សំខាន់នោះគឺលក្ខណៈនៃការចូលកាន់កាប់ដី មានប្រើអំពើហិង្សា ឬគ្មាន? កាលបរិច្ឆេទនៃការចូលកាន់កាប់ដីពិតប្រាកដដែរឬទេ? ទីតាំងក្បាលដីមានលក្ខណៈប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់រដ្ឋដែរឬទេ?

[40] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ២៤ ឧសភា ២០០២, មាត្រា៧

ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជីមានទំនាស់ដែរឬទេ? បន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ហើយ មេឃុំ ឬចៅសង្កាត់នោះត្រូវចារលើពាក្យស្នើសុំ រួចផ្ញើបែបបទទាំងអស់នោះមករដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ[41]។

– **រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ**

បន្ទាប់ពីរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ទទួលពាក្យស្នើសុំពីមេឃុំ ឬចៅសង្កាត់រួចមករដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវពិនិត្យពាក្យស្នើសុំចុះបញ្ជីដោយផ្អែកលើគោលការជំនាញ និងច្បាប់[42]៖

- ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវកត់ត្រាចូលក្នុងសៀវភៅទទួលពាក្យ និងកំណត់កាលបរិច្ឆេទនៃការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ
- ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈមិនសមស្រប រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌត្រូវចារលើពាក្យដោយបញ្ជាក់មូលហេតុដែលមិនអាចអនុវត្តនីតិវិធីនៃការចុះបញ្ជីបានហើយ អ្នកដាក់ពាក្យមានសិទ្ធិប្តឹងតវ៉ាទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង
- ក្នុងករណីពិនិត្យឃើញថា មានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះ រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ ត្រូវបញ្ជូនវិវាទនោះទៅធ្វើការសម្រុះសម្រួលនៅថ្នាក់ស្រុក-ខណ្ឌតាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី[43]។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដីទៅអ្នកដាក់ពាក្យស្នើសុំ និងត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ០៧ ( ប្រាំពីរ ) ថ្ងៃ យ៉ាងតិចមុនកាលបរិច្ឆេទនៃការកំណត់ព្រំដី នៅសាលាក្រុង ស្រុក ខណ្ឌ សាលាឃុំសង្កាត់ និងនៅទីកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ[44]។

[41] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី១

[42] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ១៩ មិនា ២០០៤, ដំណាក់កាលទី១

[43] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ២៤ ឧសភា ២០០២, មាត្រា៨

[44] អនុក្រឹត្យលេខ១២១ អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៩ មិថុនា ២០១៦, មាត្រា១

**២.២.១.២ អំពីកិច្ចប្រតិបត្តិការបច្ចេកទេស**

ដំណាក់កាលទី២ គឺជាដំណាក់កាលអំពីការប្រតិបត្តិបច្ចេកទេស។ ដំណាក់កាលនេះ គឺជាដំណាក់កាលកំណត់ព្រំដី និង វាស់ក្បាលដី និងការវិនិច្ឆ័យលើឯកសារ និងភស្តុតាង។

**ក. ការងារនៅទីវាល**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែង ត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជី តាមពេលវេលាដែលបានជូនដំណឹងដោយយោងតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងសេចក្តីណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ[45]។

យោងតាមការណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំជាក់ស្តែងរបស់ថ្នាក់ដឹកនាំរដ្ឋបាលសុរិយោដីស្រុក-ខណ្ឌ តាមលក្ខណៈភូមិសាស្ត្រដោយឡែកៗ ការងារវាលត្រូវបានអនុវត្តដោយមន្ត្រីជំនាញ ដោយមានការសហការ និងជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន ( មេភូមិ មេឃុំ ឬចៅសង្កាត់ )។ មន្ត្រីជំនាញដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការងារវាលមានភារកិច្ចទទួលខុសត្រូវលើការងារកំណត់ព្រំដី ការងារវាស់វែង ការងារបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់[46]។

**តួនាទីរបស់មន្ត្រីជំនាញក្នុងការអនុវត្តការងារវាល**

– **អំពីការកំណត់ព្រំដី**

នៅពេលធ្វើការកំណត់ព្រំក្បាលដី មន្ត្រីទទួលបន្ទុកត្រូវពិនិត្យឯកសារដែលមានជាភស្តុតាង និងពត៌មានជាលាយលក្ខណ៍អក្សរ និងពត៌មានផ្ទាល់មាត់ផ្សេងៗដែលទាក់ទងនឹងព្រំប្រទល់ក្បាលដីដែលស្នើសុំចុះបញ្ជី ហើយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវចុះប្រតិបត្តិការតាមពេលវេលា និងទីកន្លែងដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់អភិបាលស្រុក ខណ្ឌ
- មន្ត្រីទទួលបន្ទុកកំណត់ព្រំដីមានសិទ្ធិចូលរួមក្នុងបរិវេណដី ដើម្បីកំណត់ព្រំដី និងវាស់វែងហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់ពត៌មានដោយផ្ទាល់មាត់ ឯកសារ ឬ/និងបង្ហាញភស្តុតាងផ្សេងៗទាក់ទងនឹងព្រំដីនោះ

[45] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ២៤ ឧសភា ២០០២, មាត្រា១០ កថាខណ្ឌទី១

[46] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី២

– មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវគោរពតាមគោលការណ៍ដូចខាងក្រោមៈ

ក. ក្នុងករណីអ្នកដាក់ពាក្យ និងម្ចាស់ដីជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមការព្រមព្រៀង

ខ. ក្នុងករណីម្ចាស់ដីជាប់ព្រំមិនមានវត្តមាន ការកំណត់ព្រំដីត្រូវធ្វើដោយផ្អែកតាមឯកសារដែលមាន និងភស្តុតាងដែលជាលក្ខណរូប ជាលាយលក្ខណ៍អក្សរ និងភស្តុតាងផ្ទាល់មាត់ដែលទាក់ទងនឹងព្រំដីនោះ

គ. ក្នុងករណីក្បាលដីដែលស្នើសុំចុះបញ្ជីស្ថិតនៅជាប់នឹងដីសាធាណៈ ឬជាប់នឹងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ការកំណត់ព្រំដីត្រូវធ្វើដោយយោងតាមចំណុច ( ក ) និង ( ខ ) ខាងលើ[47]។

– **អំពីការវាស់វែង និងការកំណត់ទីតាំងក្បាលដី**

ក្រោយពីបានកំណត់ព្រំដីរួច មន្ត្រីទទួលបន្ទុកវាស់វែងត្រូវធ្វើការវាស់វែងទៅតាមតម្រូវការនៃការកសាងផែនទីក្បាលដី (parcel map) គំនូសបង្ហាញទីតាំងក្បាលដី និងផែនទីមានលក្ខណៈដាច់ដោយដុំ (sporadic index map) ក្នុងតំបន់នីមួយៗ។ ក្នុងប្រព័ន្ធនេះ ការវាស់វែងអាចប្រព្រឹត្តិទៅបានតាមវិធីពីរ អាស្រ័យទៅលើលក្ខណៈនៃភូមិសាស្ត្រ និងឧបករណ៍វាស់វែង[48]។

– **អំពីការវិនិច្ឆ័យ**

មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យមានសិទ្ធិសាកសួរយកពត៌មានសម្រាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនពាក់ព័ន្ធអោយផ្តល់ពត៌មានដោយផ្ទាល់មាត់ ឯកសារ ឬ/និងវត្ថុតាងផ្សេងៗដែលទាក់ទងនឹងការវិនិច្ឆ័យ។ មន្ត្រីទទួលបន្ទុកការងារវិនិច្ឆ័យត្រូវកំណត់កត់ត្រាពត៌មានអំពីម្ចាស់ដីក្បាលដីព្រមទាំងសិទ្ធិ និងបន្ទុកទាំងអស់ដែលមានលើក្បាលដី ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចអោយអ្នកពាក់ព័ន្ធទាំងអស់ផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យនោះក៏ត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ។ បន្ទាប់មក ទម្រង់បែបបទនេះក៏ត្រូវដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌពិនិត្យ និងចុះហត្ថលេខាបញ្ជាក់[49]។

[47] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី២

[48] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ១៩ មិនា ២០០៤, ដំណាក់កាលទី២

[49] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ១៩ មិនា ២០០៤, ដំណាក់កាលទី២

ចំពោះដីភោគៈ ការវិនិច្ឆ័យត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម[50]៖

ក. ដីដែលបានចុះបញ្ជី ត្រូវបានកាន់កាប់មុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

ខ. ដីដែលស្នើសុំចុះបញ្ជី ត្រូវបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់។

**អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់**

អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការងារកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ដោយផ្តល់ពត៌មានពិតដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីរបស់ខ្លួន ឬក្បាលដីដែលខ្លួនត្រូវបានចាត់តាំងធ្វើជាតំណាង ឬក្បាលដីអ្នកជាប់ព្រំជូនមន្ត្រីជំនាញ។ ក្នុងរយៈពេលប្រតិបត្តិការរបស់មន្ត្រីជំនាញ អ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ ឬជនមានប្រយោជន៍ពាក់ព័ន្ធ មានសិទ្ធិជំទាស់ ប្រសិនបើខ្លួនដឹងថា ទិន្នន័យដែលមន្ត្រីជំនាញបានកត់ត្រាចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យ ឬឯកសារផ្សេងទៀតទាក់ទងនឹងការវិនិច្ឆ័យនោះមិនត្រឹមត្រូវ ឬខុសពីចម្លើយរបស់ខ្លួន[51]។

**ក.អំពីសិទ្ធិភារកិច្ចរបស់អាជ្ញាធរដែនដី**

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កលក្ខណៈងាយស្រួល សហការឱ្យបានល្អ និងផ្តល់សុវត្ថិភាពដល់កិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីឱ្យសម្រេចនូវការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ។ ក្នុងករណីចាំបាច់ រដ្ឋបាលសុរិយោដីអាចស្នើសុំទៅអាជ្ញាធរដែនដី ឬកម្លាំងអាវុធឱ្យជួយជ្រោមជ្រែងដល់ការអនុវត្តការងារវាល[52]។

ក្នុងការផ្តល់យោបល់លើពាក្យស្នើសុំ ឬឯកសារពត៌មានពាក់ព័ន្ធនឹងការកំណត់សិទ្ធិលើដីពិសេសការផ្តល់យោបល់ទាក់ទងនឹងលក្ខខណ្ឌនៃការកាន់កាប់ដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ដី ត្រូវតែជាពត៌មានពិត មិនបំភ្លៃ បំភាន់ ឬផ្អែកលើមនោសញ្ចេតនាបុគ្គលដែលជាហេតុនាំឱ្យការកំណត់សិទ្ធិលើអចលនវត្ថុមិនត្រឹមត្រូវ និងនាំឱ្យមានទំនាស់[53]។

[50] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៣១ ឧសភា ២០០២, មាត្រា១១

[51] សារាចរណែនាំលេខ០១ដនស/សដ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី២

[52] សារាចរណែនាំលេខ០១ដនស/សដ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី២

[53] សារាចរណែនាំលេខ០១ដនស/សដ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី២

**ខ. ការងារនៅការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាលមានគុណភាពពីរ៖

- ទី១ អាចបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីកសាងផែនទីក្បាលដី ផែនទីបង្ហាញទីតាំងដីស្នើសុំ ផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុ ចំពោះក្បាលដីទាំងឡាយដែលការវាស់វែង ត្រូវបានធ្វើឡើងដោយឧបករណ៍ទំនើប។
- ទី២ អាចគូរផែនទីក្បាលដី គូរគំនូសបង្ហាញទីតាំងដីស្នើសុំ ផែនដីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីអចលនវត្ថុ ចំពោះក្បាលដីដែលការវាស់វែង ត្រូវបានធ្វើឡើងដោយឧបករណ៍សាមញ្ញ។

របៀបរៀបចំខ្លឹមសារ និងការកាន់កាប់ឯកសារសុរិយោដី៖ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីអចលនវត្ថុ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី ផែនទីក្បាលដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងឯកសារណាបផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូនីយកម្ម និងសំណង់[54]។

**២.២.១.៣ អំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ដំណាក់កាលទី៣ គឺជាដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ។ ដំណាក់កាលនេះ មានរយៈពេល១៥ ( ដប់ប្រាំ ) ថ្ងៃ និងអាចមានសិទ្ធិជំទាស់ ឬតវ៉ាបាន។

បន្ទាប់ពីការពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេស រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។

ឯកសារនៃការវិនិច្ឆ័យដែលត្រូវផ្សព្វផ្សាយ រួមមាន ផែនទីក្បាលដី គំនូសបង្ហាញទីតាំងដី និងបញ្ជីឈ្មោះម្ចាស់ដី។ ការផ្សព្វផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យត្រូវធ្វើឡើងរយៈពេល១៥ ( ដប់ប្រាំ ) ថ្ងៃ នៅសាលាក្រុង ស្រុក ខណ្ឌដែលមានសមត្ថកិច្ច។ សេចក្តីចម្លងនៃឯកសារទាំងនេះក៏ត្រូវបិទផ្សាយផងដែរនៅទីស្នាក់ការឃុំ សង្កាត់ដែលក្បាលដីស្នើសុំចុះបញ្ជីនោះស្ថិតនៅ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យនេះដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដី។ សេចក្តីជូនដំណឹងត្រូវធ្វើឡើងយ៉ាងតិច៣ ( បី ) ថ្ងៃ

[54] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៩, ដំណាក់កាលទី២

មុនថ្ងៃបើការផ្សព្វផ្សាយជាសាធារណៈ ហើយត្រូវបិទផ្សាយនៅកន្លែងដែលងាយមើលឃើញក្នុងភូមិ នៅសាលាឃុំ សង្កាត់ និងនៅសាលាក្រុង ស្រុក ខណ្ឌ[55]។

ក្នុងរយៈពេលនៃការបិទផ្សាយ សាម៉ីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីស្នើចុះបញ្ជី អាចជូនដំណឹងពីការជំទាស់របស់ខ្លួន ឬធ្វើបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់អ្នកប្រចាំការកន្លែងបិទផ្សាយ។ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវស៊ើបអង្កេតលើការជំទាស់នោះ ដោយផ្អែកតាមឯកសារ និងព័តមានទាំងអស់ដែលប្រមូលបានក្នុងពេលអនុវត្តនីតិវិធី។

ករណីដែលការស៊ើបអង្កេតនោះបង្ហាញថា ការជំទាស់ ឬការតវ៉ាមានលក្ខណៈមិនសមហេតុផល និងដោះស្រាយតាមនីតិវិធីដែលមានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

បណ្តឹងនីមួយៗត្រូវធ្វើកំណត់ដោយឡែក ហើយត្រូវបញ្ជាក់អំពីកម្មវត្ថុនៃបណ្តឹងឈ្មោះ និងស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីកត់ត្រា និងមានការបញ្ជាក់ដឹងលឺពីមេឃុំ ចៅសង្កាត់ ឬ តំណាង។

ក្នុងករណីមិនមានការជំទាស់ ឬតវ៉ា ក្នុងរយៈពេលនៃការបិទផ្សព្វផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ ត្រូវចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការបាន[56]។

**២.២.១.៤ ការសម្រេចលើឯកសារ**

ដំណាក់កាលទី៤ គឺជាដំណាក់កាលសម្រេចលើឯកសារ។ ដំណាក់កាលនេះ គឺមន្ត្រីជំនាញធ្វើរបាយការណ៍ និង ពិនិត្យ និងចុះហត្ថលេខា។ក្រោយពីផុតរយៈពេលនៃការបរិច្ឆេទបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យមន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ តាមខ្លឹមសារដូចជា៖

- លទ្ធផលសម្រេចបាន
- មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវធ្វើការវាយតម្លៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុជូនអ្នកកាន់កាប់ដែលបានស្នើសុំ

[55] អនុក្រឹត្យលេខ១២១ អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៩ មិថុនា ២០១៦, មាត្រា១

[56] សារាចរណែនាំលេខ០១ដនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី៣

- មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ[57]។

ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីត្រូវបានកែតម្រូវរួចហើយមន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំ ត្រូវរៀបចំសំណុំឯកសារ ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌពិនិត្យ និងបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង[58]។រដ្ឋបាលសុរិយោដីស្រុក ខណ្ឌត្រូវផ្ញើសំណុំឯកសារទៅរដ្ឋបាលសុរិយោដីខេត្ត ក្រុង ដូចខាងក្រោមៈ

- ពាក្យស្នើសុំចុះបញ្ជីដី
- ឯកសារនៃការវិនិច្ឆ័យ
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈ
- របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន
- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន។

ក្នុងករណីដែលពិនិត្យឃើញថាឯកសារទាំងនោះគ្រប់គ្រាន់ និងត្រឹមត្រូវហើយ រដ្ឋបាលសុរិយោដីខេត្ត ក្រុងត្រូវចុះហត្ថលេខា រួចបញ្ជូនទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល[59]។

### ២.២.១.៥ អំពីការចេញប័ណ្ណ

ដំណាក់កាលទី៥ គឺការចេញប័ណ្ណ។

បន្ទាប់ពីបានទទួលសំណុំរឿងពីរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ រដ្ឋបាលសុរិយោដីខេត្ត ក្រុងត្រូវៈ

- ពិនិត្យ និងផ្តល់យោបល់ជូនអភិបាលខេត្ត-ក្រុង សម្រេចយល់ព្រមឱ្យចេញប័ណ្ណ ឬជំទាស់ត្រង់ចំណុចណា ឬច្រានចោលទាំងស្រុងតែម្តង។

ក្នុងករណីអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រមឱ្យចេញប័ណ្ណ រដ្ឋបាលសុរិយោដីខេត្ត-ក្រុងដែលបានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាល អាចចេញប័ណ្ណ

---

[57] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី៤

[58] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី៤

[59] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៣១ ឧសភា ២០០២, មាត្រា ១៦

ជូនសាម៉ីអ្នកស្នើសុំតែម្តង។ ប៉ុន្តែ ក្នុងករណីអភិបាលខេត្ត-ក្រុងជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោល អភិបាលខេត្ត-ក្រុងនោះត្រូវបញ្ជាក់ឱ្យច្បាស់ពីមូលហេតុនៃការជំទាស់ ឬការច្រានចោលនោះ ដើម្បីរដ្ឋបាលសុរិយោដីជម្រាបទៅអ្នកស្នើសុំឱ្យបានជ្រាប។

– ពិនិត្យ និងផ្តល់យោបល់ជូនអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រម ឬជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោលមិនផ្តល់ប័ណ្ណជូនអ្នកស្នើសុំ។

ករណីអភិបាលខេត្ត-ក្រុងសម្រេចយល់ព្រម រដ្ឋបាលសុរិយោដីខេត្ត ក្រុងដែលមិនទាន់បានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាល ត្រូវបញ្ជូនសំណុំរឿងនេះបន្ត មកអគ្គនាយកដ្ឋាន និងភូមិសាស្ត្រដើម្បីពិនិត្យ។ បើមានចំណុចណាមិនទាន់ត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ អគ្គនាយកដ្ឋាន និងភូមិសាស្ត្រត្រូវណែនាំរដ្ឋបាលសុរិយោដីខេត្ត-ក្រុង កែតម្រូវ ឬបំពេញឡើងវិញដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ជាមូលដ្ឋាន។

ប៉ុន្តែ ក្នុងករណីអភិបាលខេត្ត-ក្រុងជំទាស់ចំណុចណាមួយ ឬច្រានចោលទាំងស្រុងតែម្តង រដ្ឋបាលសុរិយោខេត្ត-ក្រុងត្រូវពិនិត្យមើលចំណុចនោះឡើងវិញ ហើយរាយការណ៍សុំយោបល់អភិបាលខេត្ត-ក្រុងនោះជាលើកទីពីរ។ ករណីអភិបាលខេត្ត-ក្រុងនៅតែរក្សាការសម្រេចចិត្តដូចករណីដែលបានរៀបរាប់ខាងលើ រដ្ឋបាលសុរិយោដីខេត្ត-ក្រុងត្រូវបញ្ជូនសំណុំរឿងនោះមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដោយភ្ជាប់យោបល់ជំទាស់ ឬច្រានចោល និងរបាយការណ៍ពិនិត្យឡើងវិញមកជាមួយ ដើម្បីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រពិនិត្យ និងសម្រេច[60]។

## ២.២.១.៦គោលការណ៍នៃការចេញប័ណ្ណ

1. សមត្ថកិច្ចក្នុងការសម្រេចលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងការចេញប័ណ្ណដីត្រូវប្រគល់សិទ្ធិជូនរដ្ឋបាលសុរិយោដីខេត្ត-ក្រុងលើកលែងតែដីដែលមានទំហំលើសពី២០ហិកតាឡើងទៅត្រូវសម្រេចដោយរដ្ឋបាលសុរិយោដីថ្នាក់កណ្តាល
2. ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ( ប័ណ្ណកម្មសិទ្ធិ ) ជូនចំពោះក្បាលដីណាដែលម្ចាស់កម្មសិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់

[60] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤, ដំណាក់កាលទី៥

3. ចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ( ប័ណ្ណភោគៈ ) ជូនចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយមានរយៈពេលតិចជាង៥ឆ្នាំ
4. អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដីណាដែលគ្មានទាក់ទិននឹងវិវាទ ឬមានវិវាទតែត្រូវបានដោះស្រាយចប់ជាស្ថាពរ
5. មិនអាចចេញប័ណ្ណជូនបានទេចំពោះក្បាលដីដែលអ្នកស្នើសុំបានចូលកាន់កាប់ដី ក្រោយច្បាប់ភូមិបាលចូលជាធរមាន
6. មិនអាចចេញប័ណ្ណជូនបានជាឯកជនបានទេ ចំពោះក្បាលដីណាដែលត្រូវបានកំណត់ទាំងស្រុងជាទ្រព្យសម្បត្តិសាធារណៈ ឬទុកបម្រើសេវាសាធារណៈ
7. នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដីត្រូវប្រគល់ឯកសារទាំងអស់ទាក់ទងនឹងសិទ្ធិលើក្បាលដីនោះដែលខ្លួនមានពីមុន មកជូនមន្ត្រីសុរិយោដី
8. ការប្រគល់ប័ណ្ណដីត្រូវបានធ្វើឡើងដោយមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាងផងដែរ
9. ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព ឬនាមករណ៍ ( នីតិបុគ្គលសាធារណៈមានជាអាទិ៍ សាលារៀន សាលាឃុំ... នីតិបុគ្គលឯកជនមានជាអាទិ៍ សមាគម ក្រុមហ៊ុន...) គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជា វត្ត ឬសហគមន៍ជនជាតិដើមភាគតិច... នៅក្នុងប័ណ្ណ ក៏ត្រូវចុះឈ្មោះវត្ត ឬសហគមន៍...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គល ជាតំណាងឡើយ[61]។

បន្ទាប់ពីក្បាលដីត្រូវបានចុះបញ្ជីរួច រដ្ឋបាលសុរិយោដីត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឱ្យកម្មសិទ្ធិករនៃក្បាលដីដែលបានចុះបញ្ជី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុឱ្យភាគីដែលបានចុះបញ្ជី[62]។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់សិទ្ធិឱ្យខេត្ត ក្រុងណា ដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ[63]។

---

[61] សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៥, ដំណាក់កាលទី៥

[62] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៣១ ឧសភា ២០០២, មាត្រា១៨ កថាខណ្ឌ១

[63] អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៣១ ឧសភា ២០០២, មាត្រា១៨ កថាខណ្ឌ២

### ❖ សោហ៊ុយសេវានៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ

សោហ៊ុយសេវានៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំត្រូវបានកំណត់ដូចខាងក្រោម[64]៖

| II. សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | |
|---|---|---|---|---|---|
| ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈដាច់ដោយដុំ ឬ ការចុះបញ្ជីដីបំពេញបន្ថែម (ក្នុង១ក្បាលដី) | | | | | |
| លរ. | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរិមានៃការផ្តល់សេវា | សុពលភាព | សេចក្តីផ្សេងៗ |
| | ១. ដីផលិតកម្មកសិកម្ម | | | | |
| ២៧៨ | ដីក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ព្រះសីហនុ និងសៀមរាម | ៤០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៤០ ០០០ រៀលក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជាចំនួនគត់មិនគិតចំនួនក្បៀស) |
| ២៧៩ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ព្រះសីហនុ និងសៀមរាម | ៣០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី៥ហិកតា បន្ថែម៣០ ០០០ រៀលក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជាចំនួនគត់មិនគិតចំនួនក្បៀស) |

[64] ប្រកាសលេខ ៦៩៩សហវ.ប្រក, រួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០១៦

| | | | | | |
|---|---|---|---|---|---|
| ២៨០ | ដីជនបទ ឬដីក្រៅក្រុង | ២០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី៥ហិកតា បន្ថែម២០ ០០០ រៀល ក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជាចំនួនគត់មិនគិតចំនួនក្បៀស) |
| | ២.ដីលំនៅដ្ឋាន ឬដីសាងសង់ | | | | |
| ២៨១ | ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងរបស់ខេត្តកណ្តាល ព្រះសីហនុ និងសៀមរាម | ៦០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៨០ ០០០ រៀល ក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជាចំនួនគត់មិនគិតចំនួនក្បៀស) |
| ២៨២ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ព្រះសីហនុ និងសៀមរាម | ៤០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៦០ ០០០ រៀល ក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជាចំនួនគត់មិនគិតចំនួនក្បៀស) |
| ២៨៣ | ដីជនបទ ឬដីក្រៅក្រុង | ២០០ ០០០ | ៦០ ថ្ងៃ | | បើលើសពី១ហិកតា បន្ថែម៣០ ០០០ រៀលក្នុង១ហិកតា ដែលលើស(ទំហំដែលលើសគិតជា |

| | | | | | |
|---|---|---|---|---|---|
| | | | | | ចំនួនគត់មិនគិត ចំនួនក្បៀស) |

### ២.២.២ សមិទ្ធិផលនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

ការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំនៅក្នុងខេត្តសៀមរាបគិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៧ បាន ២៥.០០១ប័ណ្ណ។

- នៅឆ្នាំ២០១៨បានចុះបញ្ជីដីដាច់ដោយដុំចំនួន ២៦៣ ក្បាលដី
- ២០១៧ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ១៦៩ ប័ណ្ណ ( គិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៧ បាន ២៥.០០១ប័ណ្ណ )
- ២០១៦ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ១១៩ ប័ណ្ណ ( គិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៦ បាន ២៤.៨៣២ប័ណ្ណ )
- ២០១៥ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ១៥៥ ប័ណ្ណណ ( គិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៥ បាន ២៤.៥៩៩ប័ណ្ណ )
- ២០១៤ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ១២០ ប័ណ្ណ ( គិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៤ បាន ២៤៤៤៤ប័ណ្ណ )

នៅឆ្នាំ២០១៧សម្រេចបាន ១៦៩ ប័ណ្ណ ( គិតពីពេលចាប់ផ្តើមរហូតដល់ខែធ្នូ ឆ្នាំ២០១៧ បាន ២៥.០០១ប័ណ្ណ )

### ២.២.៣ បញ្ហាប្រឈម

ចំពោះបញ្ហាប្រឈមទាក់ទងទៅនឹងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំវិញ ក៏មិនខុសពីបញ្ហាប្រឈមទាក់ទងទៅនឹងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដែរ។ ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំក្នុងខេត្តសៀមារប បានកំពុងប្រទះនឹងបញ្ហាជាច្រើន ដែលបានធ្វើឱ្យរាំងស្ទះដល់ការដំណើរការចុះបញ្ជីនេះ ដោយបញ្ហាទាំងនោះរួមមាន៖

- មានការលំបាកក្នុងការកំណត់ព្រំដីសាធារណៈដូចជាបឹង អូរ ប្រលាយ ផ្លូវ ដោយស្ថាប័នជំនាញពាក់ព័ន្ធមិនសូវចូលរួមកំណត់ព្រំ ទំហំដី ដែលស្ថិតនៅសមត្ថកិច្ចខ្លួនផ្ទាល់ ។
- ម្ចាស់ដីធ្វើចំណាកស្រុកដែលក្បាលដីទាំងនោះមិនអាចចុះបញ្ជីបាន ។
- ក្បាលដីស្ទើរតែ ៩០% គ្មានបង្គោលព្រំ ពេលមន្ត្រីចុះទៅដល់ក៏ចាប់ជជែកឈ្លោះនាំឱ្យខាតពេល ។
- មធ្យោបាយធ្វើដំណើរ និងសម្ភារៈឧបករណ៍មានសភាពចាស់ទ្រុឌទ្រោមខ្លាំង ។

- ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យដីធ្លី ជាពិសេសទាក់ទងនិងការអនុវត្តនីតិវិធីថ្មី មិនទាន់បានទូលំទូលាយ ។
- បរិមាណនៃឯកសារចុះបញ្ជីដីធ្លីកើនឡើងជាលំដាប់ ធ្វើឱ្យកន្លែងទុកដាក់ជួបការលំបាក
- មានការរំលោភយកដីសាធារណៈរបស់រដ្ឋពីសំណាក់ប្រជាពលរដ្ឋរួចទាមទារឱ្យមន្ទីរចេញប័ណ្ណជូនពួកគាត់ ។
- រាល់ពេលមានវិវាទ គូភាគីមិនសូវមានឆន្ទៈក្នុងការសម្រុះសម្រួលចង់ឈ្នះតែរៀងៗខ្លួន ។
- ការបញ្ជាក់ការកាន់កាប់ពីអាជ្ញាធរភូមិ ឃុំ ច្រើនតែជាន់គ្នា និងមិនបញ្ជាក់តែម្តង។
- ក្នុងដំណើរការចុះបញ្ជីដីធ្លី ក្រុមការងារវាលដែលចុះធ្វើអត្តសញ្ញាណកម្មដី និងម្ចាស់ដីនៅតាមតំបន់វិនិច្ឆ័យតែងជួបនឹងបញ្ហាប្រឈមមួយចំនួនជាអាទិ៍៖

➢ ប្រជាពលរដ្ឋជាម្ចាស់អចលនវត្ថុខ្លះ ខ្វះលិខិត និង ឯកសារណាមួយផ្សេងៗបញ្ជាក់ភាពជាម្ចាស់ស្របច្បាប់។
➢ ការចូលរួមរបស់អ្នកកាន់កាប់ដីស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋនៅមានកម្រិត
➢ ការដោះស្រាយវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យមានភាពយឺតយ៉ាវ និង ច្រើនកកស្ទះ
➢ តំបន់រងទឹកជំនន់នៅជុំវិញបឹងទន្លេសាបនារដូវវស្សាមានភាពមិនច្បាស់លាស់
➢ ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិជួបនឹងកង្វះសំណុំលិខិតពេញលេញជាមូលដ្ឋានពីសំណាក់ម្ចាស់ចំណែកឯកជន
➢ របាយការណ៍បូកសរុបទៅលើការអនុវត្តនីតិវិធីបានបង្ហាញថាមានដីទំនាស់គឺជាដីប្រភេទកសិកម្ម និង ដីលំនៅស្ថាន ជាការប្តឹងតវ៉ាទាមទារក្បាលដីមកធ្វើជាកម្មសិទ្ធិស្របច្បាប់។

- ម្ចាស់ដីខ្លះខ្វះខាតលើការដាំបង្គោលព្រំដីមិនបានរឹងមាំ ចំណែកការលក់ដូរ ឬ ដាក់បញ្ចាំពុំមានកិច្ចសន្យាច្បាស់លាស់។ម្ចាស់ដីមួយចំនួនទៀត ពួកគាត់ដណ្តើមដីគ្នាទៅវិញទៅមកមិនចង់ដាក់ថាជាដីរួមគ្នាទេព្រោះមានទំនាស់ផ្ទៃក្នុងនៅក្នុងគ្រួសារ។
- ភាពយឺតយ៉ាវខ្លះដែរចំពោះការបញ្ជូនឯកសារមួយចំនួនដូចជា ការផ្ទេរលិខិតទាំង លិខិតអញ្ជើញ លិខិតស្នើសុំ សេចក្តីសម្រេច សេចក្តីជូនដំណឹងផងដែរគឺត្រូវប្រើពេលវេលារង់ចាំច្រើនថ្ងៃទើបទទួលបានហត្ថលេខា ដើម្បីយកទៅអនុវត្តបន្ត។ លើសពីនេះទៅទៀតសូម្បីតាមរបាយការណ៍ចុះត្រួតពិនិត្យគុណភាពក្បាលដី ក៏មានការយឺតយ៉ាវដែរព្រោះតែឯកសារដែលត្រូវបំពេញខ្វះស្នាមមេដៃប្តី ពេលខ្លះខ្វះស្នាមមេដៃប្រពន្ធ ជាពិសេសមានការប្តូរឈ្មោះមិនច្បាស់លាស់ ដែលជាមូលហេតុពិបាកយឺតពេលក្នុងការស្រង់យកពត៌មានដាក់

ក្នុងឯកសារប្រមូលទិន្នន័យក្បាលដី។មួយវិញទៀត ចំពោះម្ចាស់ដីខ្លះក៏ពុំបានចូលរួមឱ្យបានទាន់ពេលវេលាលើការកំណត់ព្រំក្បាលដី និង ការវិនិច្ឆ័យធ្វើឱ្យយឺតយ៉ាវលើការប្រមូលទិន្នន័យក្បាលដី។

- ម្ចាស់ដីខ្លះមិនទាន់មានអត្តសញ្ញាណប័ណ្ណគ្រប់គ្រាន់ ខ្វះសារតាឪពុកម្ដាយម្ចាស់កម្មសិទ្ធិជាមួយគ្នានេះដែរគ្រួសារមួយចំនួនលែងលះ ឬ ចុះចោលដោយពុំមានការបញ្ជាក់ច្បាស់លាស់នាំឱ្យលំបាកក្នុងការកំណត់សិទ្ធិក៏ជាហេតុបង្កជាទំនាស់លើដីធ្លីពេលធ្វើការចុះបញ្ជី។
- ប្រជាពលរដ្ឋនៅមិនទាន់យល់ពីនីតិវិធីការចុះបញ្ជីដី និង ច្បាប់មួយចំនួនដែលពាក់ព័ន្ធនិងដីធ្លីនិង ការអនុវត្តផ្សេងៗដើម្បីទទួលបានកម្មសិទ្ធិ ឬ វិញ្ញាបនបត្រ ព្រោះកន្លងមកមិនទាន់មានការចុះទៅពន្យល់ណែនាំអំពី ច្បាប់ បញ្ញាត្តិ និង គោលការណ៍នានាដែលពាក់ព័ន្ធនិងការកាន់កាប់ប្រើប្រាស់គ្រប់គ្រងដីធ្លីឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។ហើយនៅមិនទាន់មានច្បាប់កំណត់ពី ចំណីអូរ ប្រឡាយ ផ្លូវលំ ជាហេតុនាំឱ្យមន្ត្រីជំនាញមានការស្ទាក់ស្ទើរក្នុងការរក្សាទុក ឬ ប្រគល់សិទ្ធិឱ្យជាឯកជនដល់ប្រជាពលរដ្ឋ។ មួយវិញទៀតការផ្សព្វផ្សាយនៅមានកម្រិត ពេលខ្លះពួកគាត់មិនបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលផ្សេងៗទាក់ទងនិងដីធ្លី។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវចំពោះប្រធានបទស្តីពីការចុះបញ្ជីដីធ្លីនៅខេត្តសៀមរាប បានបង្ហាញថា មានលក្ខណៈដូចទៅនឹងការចុះបញ្ជីនៅទូទាំងប្រទេសកម្ពុជាដែរ។ សំដៅត្រង់ថា នីតិវិធីក្នុងការចុះបញ្ជីដីធ្លីមាន៥ដំណាក់កាល ដូចគ្នា រួមមានដំណាក់កាលត្រៀមរៀបចំ ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ដំណាក់កាលបិទផ្សាយជាសាធារណៈ ដំណាក់កាលសម្រេចលើឯកសារ និង ដំណាក់កាលចុងក្រោយគឺ ដំណាក់កាលនៃការចែកប័ណ្ណ។ ជាមួយគ្នានេះដែរក្នុងដំណាក់កាលនីមួយៗ ការចុះបញ្ជីដីធ្លីនៅខេត្តសៀមរាបមានទាំលក្ខណៈល្អប្រសើរផង និងភាពមិនស៊ីចង្វាក់គ្នាខ្លះរវាងបទបញ្ញត្តិ និងការអនុវត្តផងដែរ។ ភាពមិនស៊ីចង្វាក់គ្នានេះសំដៅលើការ ការខ្វះខាតវិធានក្នុងការផ្សព្វផ្សាយជាមុន នៅក្នុងនីតិវិធីចាប់តាំងពីដំបូងរហូត ដំណាក់កាលចែកប័ណ្ណ។ ម្យ៉ាងវិញទៀត បើធៀបគ្នារវាងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីលក្ខណជាប្រព័ន្ធ យើងថាការអនុវត្តការចុះបញ្ជីលក្ខណៈជាប្រព័ន្ធមានច្រើនជាង រីឯការចុះបញ្ជីលក្ខណៈដាច់ដោយដុំមានតិចតួច មានតិចតួច។ លទ្ធផលនេះបង្ហាញពី ការខ្វះខាតការយល់ដឹងពីផលប្រយោជន៍នៃការចុះបញ្ជីដីធ្លី កាខ្វះមន្ត្រីជំនាញ តម្លៃនិងនីតិវិធីក្នុងការអនុវត្តការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ។ ចំណែកឯការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធមានច្រើនដោយសារតែមានច្រើន ដោយសារតែ ការប្រតិបត្តិការឡើងដោយថវិការរបស់រដ្ឋ មានការកំនត់នូវនីតិវិធីមួយសមស្របដែរអាចឱ្យប្រជាពលរដ្ឋទទួលបាននូវភាពងាយស្រួលជាងការចុះបញ្ជីដីធ្លីដាច់ដោយដុំ ។

ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពដីធ្លីនៅក្នុងខេត្តសៀមរាមកំពុងមានលក្ខណៈល្អតម្លៃមានការកើនឡើងជាលំដាប់ជាហេតុនាំឱ្យមានចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំមានការកើនឡើង។ ដូចនេះរាជរដ្ឋាភិបាលគួរតែមានបង្កើតឱ្យមានវគ្គបណ្តុះបណ្តាល និងវគ្គសិក្សាពីបច្ចេកទេសបន្ថែមទៀត ដល់មន្ត្រីផ្ទាល់ក្នុងខេត្តសៀមរាប ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលាពីការវិវត្តស្ថានភាពដីធ្លី។

# អនុសាសន៍

តាមរយៈការស្រាវជ្រាវខាងលើសបញ្ជាក់ឱ្យឃើញថាការចុះបញ្ជីដីធ្លីពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋគ្រប់រូបដែលជាម្ចាស់ដីពិតប្រាកដ និងជាកិច្ចការសំខាន់មួយដែលមិនអាចមើលរំលងបានឡើយ។ រហូតមកដល់បច្ចុប្បន្ននេះ ទាក់ទងទៅនឹងបញ្ហានៃការចុះបញ្ជីដីធ្លីយើងឃើញថា មានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាល ប៉ុន្តែនៅតែមានបញ្ហាមួយចំនួនតូចនៅតែពុំទាន់ដោះស្រាយបាន។ហេតុនេះ ដើម្បីជៀសផុតពីវិវាទដីធ្លី ចាំបាច់ត្រូវតែមានការចូលរួមយ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាលនិងភាគីដែលពាក់ព័ន្ធដូចនេះចាំបាច់ត្រូវះ

- ផ្សព្វផ្សាយច្បាប់អោយបានទូលាយ ដើម្បីឱ្យប្រជាជនទទួលបានចំនេះដឹង ឬការដឹងលឺទាក់ទងទៅនឹងបញ្ហាការចុះបញ្ជីដីដែលធ្វើឱ្យការចូលរួមរបស់ពួកគាត់មានភាពសកម្ម និងបង្កភាពងាយស្រួលក្នុងការវាស់វែងដល់មន្ត្រីជំនាញ។
- រៀបចំកែប្រែពន្លឿននីតិវិធីកុំឱ្យមានភាពស្មុគស្មាញ ហើយមានរយៈពេលខ្លីនៅក្នុងការចុះបញ្ជីដី។
- រៀបចំតាក់តែងច្បាប់ ឬ បទដ្ឋានគតិយុត្តបន្ថែមដែលងាយស្រួលក្នុងការគ្រប់គ្រងដីធ្លី និងមានប្រសិទ្ធិភាពខ្ពស់។
- ពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។
- បណ្តុះបណ្តាលមន្ត្រីជំនាញបន្ថែមទៀតឱ្យបានច្រើន ដើម្បីពន្លឿនការងារចុះបញ្ជីដីធ្លីឱ្យបានច្រើនជាងមុន និងមានប្រសិទ្ធិភាព ដើម្បីឆ្លើយតបនឹងទំហំការងារជាក់ស្តែង ដោយរាជរដ្ឋាភិបាលគួរបង្កើននូវកញ្ចប់ថវិកា ឬស្វះស្វែងរកជំនួយដើម្បីពង្រីកកិច្ចប្រតិបត្តិការនៃការចុះបញ្ជីដីធ្លី។
- បង្កលក្ខណៈងាយស្រួលដល់មន្ត្រីចុះវាស់វែង ដោយមាននូវឧបករណ៍ដែលមានលក្ខណៈទំនើប និងមានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់។
- ចុះពន្យល់ណែនាំប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានអំពីសារៈប្រយោជន៍នៃការចុះបញ្ជី និងអំពីចក្ខុវិស័យនៃកម្មវិធីគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល។
- ធ្វើការកែប្រែបន្ថែមអំពីតារាងតម្លៃសេវា ដើម្បីឱ្យប្រជាពលរដ្ឋងាយស្រួលមើល និងអាចយល់បានច្បាស់លាស់។
- បង្កើននូវទម្ងន់នៃការផ្តន្ទាទោសឱ្យកាន់តែធ្ងន់ធ្ងរ នូវមន្ត្រីទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយនឹងមុខងារក្នុងពេលចុះប្រតិបត្តិការ ឬមានការលំអៀង ឬស៊ីសំណូកក្នុងករណីណាមួយដែលកើតឡើង។

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្ត**

**ច្បាប់**

- ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧
- ច្បាប់ភូមិបាល, នស/រកម/០៨០១, ៣០ សីហា ២០០១

**អនុក្រឹត្យ**

- អនុក្រឹត្យ លេខ១២១ អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ៩ មិថុនា ២០១៦
- អនុក្រឹត្យលេខ ១២២អនក្រ/បក, ស្តីពីការកែសម្រួលមាត្រា៦ មាត្រា ៧ និងមាត្រា១១ នៃ អនុក្រឹត្យលេខ ៤៦ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, ៩ មិថុនា ២០១៦
- អនុក្រឹត្យលេខ ១៩ អនក្រ/បក, ស្តីពីសម្បទានសង្គមកិច្ច, ១៩ មិនា ២០០៣
- អនុក្រឹត្យលេខ៤៨អនក្រ/បក, ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ,៣១ឧសភា ២០០២
- អនុក្រឹត្យលេខ ៤៦អនក្រ/បក, ស្តីពីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីក្បាលដី, ៣១ ឧសភា ២០០២

**ប្រកាស**

- ប្រកាសលេខ ៦៤៩សហវ.ប្រក,រួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០១៦
- ប្រកាសលេខ ២៣៨ ប្រក/បក, ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យលំនៅឋានចំណុះឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី និងផ្នែកលំនៅឋានចំណុះការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល, ១២ ធ្នូ ២០១៤

- ប្រកាសលេខ៧៦ប្រក, ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត-ក្រុង និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ, ០២ កញ្ញា ១៩៩៩

**សារាចរ**

- សារាចរណែនាំលេខ០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ១៩ មិនា ២០០៤
- សារាចរណែនាំលេខ ០០១ជនស/សជ, ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ), ១៩ សីហា ២០០២

**សេចក្តីថ្លែងការណ៍**

- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលលេខ២៧សជណ/អគ, ស្តីពីគោលនយោបាយដីធ្លី, ០១ កក្កដា ២០០៩

**របាយការណ៍**

- សន្និបាតបូកសរុបការងារឆ្នាំ២០១៤ដល់ឆ្នាំ២០១៨

**សៀវភៅ**

- សាស្ត្រាចារ្យ ហាប់ ផល្វី, "នីតិទ្រព្យសម្បត្តិ" ២០១៥

# បញ្ជីឧបសម្ព័ន្ធ


| | | |
|---|---|---|
| ឧបសម្ព័ន្ធ១ | : | សេចក្តីសម្រេចដែលពាក់ព័ន្ធនឹងដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ |
| ឧបសម្ព័ន្ធ២ | : | ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ |
| ឧបសម្ព័ន្ធ៣ | : | រូបភាពនៃនីតិវិធីនៃការចុះបញ្ជីដីធ្លី |
| ឧបសម្ព័ន្ធ៤ | : | គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចាស់និងគំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុថ្មី |
| ឧបសម្ព័ន្ធ៥ | : | របាយការណ៍បូកសរុបលទ្ធផលនៃការចុះបញ្ជីដីខេត្តសៀមរាប |